# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងសុខាភិបាល

### សេចក្តីសម្រេច

### ស្តីពី

### ការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាក
### នៅក្នុងព្រះរាជាណាចក្រកម្ពុជា

គណៈគិលានុបដ្ឋាកកម្ពុជា
CAMBODIAN COUNCIL OF NURSES

ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០២២

ឧបត្ថម្ភដោយ

USAID FROM THE AMERICAN PEOPLE

fhi360 THE SCIENCE OF IMPROVING LIVES

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

លេខ....០១.៨...សនក

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាក
## នៅក្នុងព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនិងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៦/០១៤ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៧៣ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈគិលានុបដ្ឋាកកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីបែបបទ និងលក្ខខណ្ឌ នៃការអនុញ្ញាតឱ្យជនបរទេសជាអ្នកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រប្រកបវិជ្ជាជីវៈឯកជនក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាល ក្នុងវិស័យសុខាភិបាល



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីក្រមសីលធម៌គិលានុបដ្ឋាក
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

## សម្រេច

**ប្រការ១** .-

ត្រូវបានដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាកក្នុងព្រះរាជាណាចក្រកម្ពុជាដែលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ២** .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣** .-

នាយកខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស សុខាភិបាលអគ្គាធិការ ប្រធានអង្គភាពក្រោមឱវាទក្រសួងសុខាភិបាល និងគ្រប់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាលត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១២រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០២២

**ម៉ម_ប៊ុនហេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# សេចក្ដីថ្លែងអំណរគុណ

និយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាក ត្រូវបានបង្កើតឡើងដោយ ក្រុមការងារបច្ចេកទេសដែលត្រូវបានដឹកនាំដោយ គណៈគិលានុបដ្ឋាកកម្ពុជាដោយមានជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីគម្រោងលើកកម្ពស់សេវាថែទាំសុខភាពរបស់ ទីភ្នាក់ងារជំនួយសហរដ្ឋអាមេរិក (USAID-EQHA)។

តាំងនាមឱ្យគណៈគិលានុបដ្ឋាកកម្ពុជាខ្ញុំបាទសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តម សាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាលចំពោះការគាំទ្រយ៉ាងពេញទំហឹងសម្រាប់ការរៀបចំបង្កើតនិយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាក និងសូមសម្តែងអំណរគុណចំពោះ **ឯកឧត្តមសាស្ត្រាចារ្យ ឆា គ្រុយ**រដ្ឋលេខាធិការក្រសួងសុខាភិបាលចំពោះការសម្របសម្រួលយ៉ាងយកចិត្តទុកដាក់ក្នុងដំណើរការអភិវឌ្ឍឯកសារនេះឡើង។ សូមថ្លែងអំណរគុណផងដែរជូនចំពោះលោក លោកស្រី ក្រុមការងារគណៈគិលានុបដ្ឋាកទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានអញ្ជើញមកពីមន្ទីរសុខាភិបាលខេត្តមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព គ្រូបណ្ដុះបណ្ដាលផ្នែកថែទាំដែលអញ្ជើញមកពីគ្រឹះស្ថានបណ្ដុះបណ្ដាលសាធារណៈ និងឯកជន សមាគមគិលានុបដ្ឋាកកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលផ្នែកសុខាភិបាល និងដៃគូអភិវឌ្ឍនានា ព្រមទាំងអ្នកផ្ដល់ប្រឹក្សាយោបល់ពីខាងក្រៅដែលបានចូលរួម និងចំណាយពេលវេលាដ៏មានតម្លៃជាពិសេសការខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍឱ្យមានការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាក។

លើសពីនេះទៅទៀតខ្ញុំសូមថ្លែងអំណរគុណដ៏ស្មោះជូនចំពោះនាយកដ្ឋានមន្ទីរពេទ្យនាយកដ្ឋានអភិវឌ្ឍធនធានមនុស្សនាយកដ្ឋាននីតិកម្ម និងក្រុមប្រឹក្សាគណៈវិជ្ជាជីវៈសុខាភិបាលដែលបានរួមចំណែកអភិវឌ្ឍការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាកកម្ពុជា។

ជាងនេះទៅទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះគម្រោង **USAID-EQHA** ដែលបានផ្ដល់ជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសសម្រាប់ការអភិវឌ្ឍបង្កើតឯកសារនេះចាប់តាំងពីពេលចាប់ផ្ដើមដំបូងប្រសិនបើគ្មានជំនួយគាំទ្របែបនេះការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាកកម្ពុជា អាចនឹងមិនត្រូវបានបង្កើតឡើងនោះឡើយ។

ខ្ញុំសូមគោរពជូនពរដល់ឯកឧត្តម លោកជំទាវ លោក-លោកស្រីទាំងអស់សូមទទួលបានសុខភាពល្អ និងជោគជ័យគ្រប់ភារកិច្ច។

ថ្ងៃចន្ទ១៤កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១
ប្រធានគណៈគិលានុបដ្ឋាកកម្ពុជា

CAMBODIA COUNCIL OF NURSES

**អនុបណ្ឌិត អ៊ុន សាន**



Sm

San

# មាតិកា


**ផ្នែកទី ១៖ សេចក្ដីផ្ដើម** ........................................ ៥

១.១ តួនាទីរបស់គណៈគិលានុបដ្ឋាកកម្ពុជា ........................................ ៥

១.២ ការអភិវឌ្ឍនិយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាក ........................................ ៦

១.៣ និយមន័យ ........................................ ៦

១.៤ បរិបទនៃការថែទាំ ........................................ ៨

១.៥ គោលការណ៍ណែនាំសម្រាប់ការអនុវត្តការថែទាំ ........................................ ៩

១.៦ គោលបំណងនៃនិយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាក ........................................ ៩

**ផ្នែកទី២៖ និយាមវិជ្ជាជីវៈនៃការអនុវត្តសម្រាប់គិលានុបដ្ឋាក** ........................................ ១០

២.១ និយាមវិជ្ជាជីវៈនៃការអនុវត្តគ្លីនិកដែលមានប្រសិទ្ធភាព ........................................ ១០

២.១.១ និយាមនៃការអនុវត្តគ្លីនិក ........................................ ១០

២.២ និយាមនៃការអនុវត្តជំនាញវិជ្ជាជីវៈដ៏មានប្រសិទ្ធភាព ........................................ ២១

២.២.១ និយាមវិជ្ជាជីវៈភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង ........................................ ២១

២.២.២ ការអនុវត្តតាមច្បាប់ ក្រមសីលធម៌ និងវិជ្ជាជីវៈ ........................................ ២៤

២.២.៣ និយាមវិជ្ជាជីវៈនៃការប្រាស្រ័យទាក់ទង ការសហការ និងការតស៊ូមតិ ... ២៧

២.២.៤ និយាមវិជ្ជាជីវៈនៃការបង្រៀន និងការសិក្សារៀនសូត្រ ........................................ ៣២

២.២.៥ និយាមនៃការអនុវត្តផ្អែកលើភស្តុតាង ការសិក្សាស្រាវជ្រាវ និងគុណភាព
នៃការថែទាំ ........................................ ៣៤

**ឧបសម្ព័ន្ធ ១៖ តារាងសមាជិកក្រុមការងារបច្ចេកទេស** ........................................ ៣៧

**ឧបសម្ព័ន្ធ ២៖ បញ្ជីឯកសារដែលត្រូវបានសិក្សាពិនិត្យ** ........................................ ៣៩




San

# ផ្នែកទី ១៖ សេចក្ដីផ្ដើម

## ១.១ តួនាទីរបស់គណៈគិលានុបដ្ឋាកកម្ពុជា

គណៈគិលានុបដ្ឋាកកម្ពុជា (គ.គិ.ក) គឺជាស្ថាប័នស្វយ័តមួយដែលមានសិទ្ធអំណាចផ្លូវច្បាប់ តាមរយៈព្រះរាជក្រឹត្យស្តីពី ការបង្កើតគណៈគិលានុបដ្ឋាកកម្ពុជាឆ្នាំ២០០៧ និងច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលឆ្នាំ២០១៦ ដើម្បីបង្កើតថែរក្សានិងលើកកម្ពស់និយាមវិជ្ជាជីវៈនៃការអនុវត្តសម្រាប់គិលានុបដ្ឋាក ដែលបានចុះបញ្ជិកានៅក្នុងប្រទេសកម្ពុជា។ តួនាទីនេះផ្តល់ឱ្យ គ.គិ.ក នូវសិទ្ធអំណាចផ្លូវច្បាប់ក្នុងការគ្រប់គ្រងគិលានុបដ្ឋាក និងការថែទាំនិងការអនុវត្តការថែទាំវេជ្ជសាស្ត្រនៅក្នុងប្រទេសកម្ពុជា ដើម្បីការពារសុខភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់នេះ គ.គិ.ក បានបង្កើតនិងអនុម័តលិខិតុបករណ៍គ្រប់គ្រងដូចជា៖ ក្រមសីលធម៌ ក្របខណ្ឌសមត្ថភាពស្នូល និយាមវិជ្ជាជីវៈនៃការអនុវត្ត និងលក្ខខណ្ឌតម្រូវសម្រាប់ការអប់រំបន្តជាចាំបាច់ ដើម្បីទទួលបានការផ្តល់អាជ្ញាបណ្ណបន្តក្នុងការប្រកបវិជ្ជាជីវៈ។ ការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាកនៅក្នុងប្រទេសកម្ពុជា ដែលមានចែងនៅក្នុងឯកសារនេះ គឺជាលិខិតុបករណ៍គ្រប់គ្រងដ៏សំខាន់ដើម្បីណែនាំតម្រង់ទិសគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពនៃសេវាវិទ្យាសាស្ត្រថែទាំ។

តួនាទីរបស់ គ.គិ.ក គឺផ្តល់សុវត្ថិភាពជូនដល់សាធារណជនតាមរយៈ៖

- ការចុះបញ្ជិកាគិលានុបដ្ឋាក ដើម្បីធានាថាពួកគេមានគុណវុឌ្ឍិ សមត្ថភាព និងសម្បទាសមស្របក្នុងការប្រកបវិជ្ជាជីវៈ ព្រមទាំងទទួលបានការអនុញ្ញាតឱ្យប្រើប្រាស់ឋានៈជាគិលានុបដ្ឋាក។
- ការចុះបញ្ជិកា ការផ្តល់អាជ្ញាបណ្ណ ការផ្តល់អាជ្ញាបណ្ណបន្តជូនដល់គិលានុបដ្ឋាក ដើម្បីធានាថាពួកគេធ្វើបច្ចុប្បន្នភាពចំណេះដឹងនិងជំនាញរបស់ពួកគេជាប្រចាំតាមរយៈការអភិវឌ្ឍវិជ្ជាជីវៈបន្ត។
- ការកំណត់និយាមវិជ្ជាជីវៈសម្រាប់ការអប់រំ និងការអនុវត្តការវិទ្យាសាស្ត្រថែទាំសម្រាប់គិលានុបដ្ឋាកនៅមុន និងក្រោយបញ្ចប់ការសិក្សា និងការអភិវឌ្ឍលិខិតុបករណ៍គ្រប់គ្រងដែលពាក់ព័ន្ធ ដូចជាក្របខណ្ឌសមត្ថភាពស្នូលសម្រាប់គិលានុបដ្ឋាក និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាក។
- ការដោះស្រាយពាក្យបណ្តឹងតវ៉ានិងកិច្ចដំណើរការវិន័យ ក្នុងករណីដែលការអនុវត្តវិជ្ជាជីវៈដោយគ្មានសមត្ថភាព ឬគ្មានក្រមសីលធម៌ ឬការរំលោភបំពាននិយាមវិជ្ជាជីវៈនៃការអនុវត្ត ឬនិយាមវិជ្ជាជីវៈនៃការអនុវត្តត្រូវបានរងការចោទប្រកាន់។

គ.គិ.ក តម្រូវឱ្យគិលានុបដ្ឋាកអនុវត្តតាមនិយាមវិជ្ជាជីវៈនៃអ្នកប្រកបវិជ្ជាជីវៈថែទាំសុខភាពមានសមត្ថភាព ដែលបំពេញតាមគ្រប់លក្ខខណ្ឌតម្រូវទាំងអស់សម្រាប់ការចុះបញ្ជិកានិងការផ្តល់អាជ្ញាបណ្ណ ដែលធ្វើបច្ចុប្បន្នភាពស្របតាមការអនុវត្តរបស់ផ្នែកវិទ្យាសាស្ត្រថែទាំដែលមានសុវត្ថិភាពនិងប្រកបដោយវិជ្ជាជីវៈ អនុលោមតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់ ក្រមច្បាប់របស់ គ.គិ.ក ព្រមទាំងគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល។

និយាមវិជ្ជាជីវៈរបស់គិលានុបដ្ឋាកនៅក្នុងប្រទេសកម្ពុជា គឺជាឯកសាររស់រវើក ហើយឯកសារនេះនឹងឆ្លងកាត់ការពិនិត្យវាយតម្លៃឡើងវិញជាប្រចាំ ដោយពិគ្រោះប្រឹក្សាយោបល់ជាមួយគិលានុបដ្ឋាកនិងភាគីពាក់ព័ន្ធដទៃទៀត។



San

## ១.២ ការអភិវឌ្ឍនិយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាក

ការអភិវឌ្ឍនិយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាក គឺជាគំនិតផ្តួចផ្តើមរបស់គណៈគិលានុបដ្ឋាកកម្ពុជា (គ.គិ.ក) ដែលទទួលបានការគាំទ្រពីក្រសួងសុខាភិបាល គម្រោងលើកកម្ពស់គុណភាពសេវាថែទាំសុខភាព របស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ(USAID-EQHA-FHI 360) មជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាលអន្តរជាតិសម្រាប់វិស័យសុខាភិបាល (I-TECH) និងមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន(UNFPA)។

ក្រុមការងារបច្ចេកទេស ត្រូវបានបង្កើតឡើងដោយ គ.គិ.ក ដើម្បីត្រួតពិនិត្យមើលការអភិវឌ្ឍ និយាមវិជ្ជាជីវៈនៃការអនុវត្ត (សូមមើលឧបសម្ព័ន្ធ ១)។ លោកស្រី Jill Iliffe មកពីសហព័ន្ធឧបនិងគិលានុបដ្ឋាកនៃប្រទេសខំមិនវែលស៍ បានផ្តល់ជំនួយគាំទ្រផ្នែកបច្ចេកទេសជូនដល់ក្រុមការងារបច្ចេកទេស។ នៅក្នុងកិច្ចប្រជុំដំបូងរបស់ក្រុមការងារវិស័យ ឬផ្នែកគន្លឹះនៃការអនុវត្តការថែទាំ វេជ្ជសាស្ត្រនៅក្នុងប្រទេសកម្ពុជា ត្រូវបានកំណត់អត្តសញ្ញាណនិងឯកភាពជាមួយគ្នាក្រោយពីបានពិនិត្យមើលយ៉ាងហ្មត់ចត់ទៅលើវិស័យនៃការអនុវត្តការវិទ្យាសាស្ត្រថែទាំពីប្រទេសដទៃ ទាំងនៅក្នុងនិងនៅក្រៅតំបន់។ អនុវិស័យនៅក្នុងវិស័យនេះ ក៏ត្រូវបានឯកភាពផងដែរដោយក្រុមការងារបច្ចេកទេស។ ដោយប្រើប្រាស់និយាមវិជ្ជាជីវៈអន្តរជាតិនិងក្នុងតំបន់ជាច្រើន និយាមវិជ្ជាជីវៈសេចក្តីព្រាងត្រូវបានបង្កើតឡើង ហើយសេចក្តីព្រាងនេះត្រូវបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ ដោយធៀបទៅនឹងឯកសារដែលមានស្រាប់រួចមកហើយនៅក្នុងប្រទេសកម្ពុជា ជាពិសេសក្រមសីលធម៌គិលានុបដ្ឋាក (២០១៤) ក្របខណ្ឌសមត្ថភាពស្នូលសម្រាប់គិលានុបដ្ឋាក (២០១២) និយាមវិជ្ជាជីវៈនៃការថែទាំ (២០១៥) សេចក្តីណែនាំស្តីពីសំណុំសកម្មភាពអតិប្បរមាឆ្នាំ២០០៨-២០១៥ និងសេចក្តីណែនាំស្តីពីសំណុំសកម្មភាពបង្គ្រប់ឆ្នាំ២០១៤។ សរុបមក ឯកសារចំនួនជាង៧០ ត្រូវបានពិនិត្យ។ និយាមវិជ្ជាជីវៈសេចក្តីព្រាង ត្រូវបានត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នដោយក្រុមការងារបច្ចេកទេស។ ការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈដែលបានមកពីក្រុមការងារបច្ចេកទេស ត្រូវបានរួមបញ្ចូលទៅក្នុងនិយាមវិជ្ជាជីវៈសេចក្តីព្រាង ដែលបន្ទាប់មកត្រូវបានក្រុមការងារបច្ចេកទេសសម្រេចបញ្ចប់ សម្រាប់ប្រគល់ជូនដល់ គ.គិ.ក។

## ១.៣ និយមន័យ

និយាមវិជ្ជាជីវៈ គឺជាឃ្លាប្រយោគដែលណែនាំ តម្រង់ទិស ចាត់ចែង និងគ្រប់គ្រងការអនុវត្តវិជ្ជាជីវៈ។ និយាមវិជ្ជាជីវៈពិពណ៌នាអំពីកម្រិតនៃការអនុវត្តការងារអប្បបរមាដែលអាចទទួលយកបានតាមការរំពឹងទុកទៅលើគិលានុបដ្ឋាកដែលបានចុះបញ្ជិកាទាំងអស់នៅក្នុងការផ្តល់ជូនការថែទាំនិងការប្រកបវិជ្ជាជីវៈដែលមានសុវត្ថិភាព។ និយាមវិជ្ជាជីវៈផ្តល់ការវាស់ស្ទង់ដ៏ស៊ីចង្វាក់គ្នាមួយសម្រាប់គិលានុបដ្ឋាកនីមួយៗ ដែលបានចុះបញ្ជិកាធៀបទៅនឹងការអនុវត្តការងារណាមួយដែលអាចយកមកវិនិច្ឆ័យបាន។ និយាមវិជ្ជាជីវៈត្រូវតែមានភាពជាក់លាក់ អាចវាស់ស្ទង់បាន អាចអនុវត្តបាន មានភាពជាក់ស្តែង និងមានយុត្តិធម៌។

សូចនាករការអនុវត្តនិយាមវិជ្ជាជីវៈ គឺជាឃ្លាប្រយោគដែលអាចវាស់ស្ទង់បាន ដែលអាចយកទៅប្រើប្រាស់ដើម្បីប៉ាន់ប្រមាណថាតើបានបំពេញតាមនិយាមវិជ្ជាជីវៈណាមួយពេញលេញដែរឬទេ។ សូចនាករការអនុវត្តនិយាមវិជ្ជាជីវៈគឺគ្រាន់តែជាសូចនាករមួយប៉ុណ្ណោះ និងមិនមានភាពដាច់ខាតនោះទេ ពោលអាចនឹងមានឃ្លាប្រយោជទៃទៀតដែលអាចយកមកប្រើប្រាស់ដើម្បីវិនិច្ឆ័យថា តើបានបំពេញគ្រប់គ្រាន់តាមនិយាមវិជ្ជាជីវៈដែរឬទេ។

គិលានុបដ្ឋាក សំដៅដល់បុគ្គលដែលបានសិក្សាចប់ដោយជោគជ័យ នូវកម្មវិធីសិក្សាជំនាញគិលានុបដ្ឋាកដោយកម្មវិធីសិក្សានោះ ត្រូវបានទទួលស្គាល់ដោយក្រសួងសុខាភិបាលនៃរាជរដ្ឋាភិបាលកម្ពុជា ឬជាបុគ្គលដែល



Sm

មានសញ្ញាបត្រសមមូល ទទួលស្គាល់ដោយស្ថាប័នពាក់ព័ន្ធក្នុងប្រទេសកម្ពុជា និងបានចុះបញ្ជិកា និងទទួលបានអាជ្ញាបណ្ណពីគណៈគិលានុបដ្ឋាកកម្ពុជា ដើម្បីប្រកបវិជ្ជាជីវៈជាគិលានុបដ្ឋាក។

គិលានុបដ្ឋាកបឋម គឺជាបុគ្គលដែលបានបញ្ចប់វគ្គសិក្សាជំនាញគិលានុបដ្ឋាកបឋមដោយជោគជ័យដោយវគ្គសិក្សានោះ បានទទួលស្គាល់ដោយក្រសួងសុខាភិបាល ឬជាបុគ្គលដែលមានសញ្ញាបត្រសមមូលទទួលស្គាល់ដោយស្ថាប័នពាក់ព័ន្ធក្នុងប្រទេសកម្ពុជា និងបានចុះបញ្ជិកា និងទទួលបានអាជ្ញាបណ្ណដើម្បីប្រកបវិជ្ជាជីវៈថែទាំដែលចេញដោយគណៈគិលានុបដ្ឋាកកម្ពុជា ក្នុងនាមជាគិលានុបដ្ឋាកបឋម។ គិលានុបដ្ឋាកបឋមគួរតែបំពេញការងារក្រោមការគ្រប់គ្រងដោយផ្ទាល់របស់គិលានុបដ្ឋាកបរិញ្ញាបត្ររង និងគិលានុបដ្ឋាកបរិញ្ញាបត្រ និងអនុវត្តភារកិច្ចថែទាំមួយចំនួនដែលត្រូវបានកំណត់។

គិលានុបដ្ឋាកបរិញ្ញាបត្ររង គឺជាបុគ្គលដែល បានបញ្ចប់វគ្គសិក្សាជំនាញបរិញ្ញាបត្ររងគិលានុបដ្ឋាកដោយជោគជ័យ ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ឬជាបុគ្គលដែលមានសញ្ញាបត្រសមមូលទទួលស្គាល់ដោយស្ថាប័នពាក់ព័ន្ធក្នុងប្រទេសកម្ពុជា និង បានចុះបញ្ជិកា និងទទួលបានអាជ្ញាបណ្ណដែលចេញដោយ គណៈគិលានុបដ្ឋាកកម្ពុជាដើម្បីប្រកបវិជ្ជាជីវៈថែទាំជាគិលានុបដ្ឋាកបរិញ្ញាបត្ររង ។

គិលានុបដ្ឋាកបរិញ្ញាបត្រ គឺជាបុគ្គលដែលបានបញ្ចប់វគ្គសិក្សាជំនាញបរិញ្ញាបត្រគិលានុបដ្ឋាកដោយជោគជ័យដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ឬជាបុគ្គលដែលមានសញ្ញាបត្រសមមូលទទួលស្គាល់ដោយស្ថាប័នពាក់ព័ន្ធក្នុងប្រទេសកម្ពុជា និងបានចុះបញ្ជិកា និងទទួលបានអាជ្ញាបណ្ណដែលចេញដោយ គណៈគិលានុបដ្ឋាកកម្ពុជាដើម្បីប្រកបវិជ្ជាជីវៈថែទាំជាគិលានុបដ្ឋាកបរិញ្ញាបត្រ ។

គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់ គឺជាគិលានុបដ្ឋាកដែលត្រូវបានចុះបញ្ជិកា និងទទួលបានអាជ្ញាបណ្ណដែលចេញដោយគណៈគិលានុបដ្ឋាកកម្ពុជា ដើម្បីប្រកបវិជ្ជាជីវៈថែទាំ និងជាគិលានុបដ្ឋាកដែលបានបញ្ចប់វគ្គបរិញ្ញាបត្រជាន់ខ្ពស់ដែលពាក់ព័ន្ធនឹងការថែទាំ ទទួលស្គាល់ដោយក្រសួងសុខាភិបាល ឬជាបុគ្គលដែលមានសញ្ញាបត្រសមមូលទទួលស្គាល់ដោយស្ថាប័នពាក់ព័ន្ធក្នុងប្រទេសកម្ពុជា និងគណៈគិលានុបដ្ឋាកកម្ពុជា។

គិលានុបដ្ឋាកបណ្ឌិត (បណ្ឌិតទស្សនៈវិទ្យាវិទ្យាសាស្ត្រថែទាំ ឬ បណ្ឌិតអនុវត្តថែទាំ) គឺជាគិលានុបដ្ឋាកដែលត្រូវបានចុះបញ្ជិកា និងទទួលបានអាជ្ញាបណ្ណដែលចេញដោយគណៈគិលានុបដ្ឋាកកម្ពុជា ដើម្បីប្រកបវិជ្ជាជីវៈថែទាំ និង ជាគិលានុបដ្ឋាកដែលបានបញ្ចប់វគ្គសិក្សាថ្នាក់បណ្ឌិតពាក់ព័ន្ធនឹងការថែទាំ ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ឬជាបុគ្គលដែលមានសញ្ញាបត្រសមមូលទទួលស្គាល់ដោយស្ថាប័នពាក់ព័ន្ធក្នុងប្រទេសកម្ពុជា និងគណៈគិលានុបដ្ឋាកកម្ពុជា។

ដំណើរការថែទាំ គឺជាក្របខ័ណ្ឌដែលបានរៀបចំឡើងដើម្បីឱ្យការអនុវត្តរបស់គិលានុបដ្ឋាកប្រកបដោយវិជ្ជាជីវៈ និងជាវិធីសាស្ត្រនៃការកំណត់អត្តសញ្ញាណនៃបញ្ហា និងការដោះស្រាយបញ្ហា ដែលវិធីសាស្ត្រនោះពណ៌នាអំពីអ្វីដែលគិលានុបដ្ឋាកត្រូវធ្វើ[1] ។ ទ្រឹស្តីមួយដែលត្រូវបានបង្កើតឡើងដោយ [2] នៅឆ្នាំ១៩៥៨ Ida Jean Orlando ស្តីពីរបៀបអនុវត្តការថែទាំនិងត្រូវបានចាត់ទុកថាជាស្នូលដ៏សំខាន់នៃការអនុវត្តវិជ្ជាជីវៈ ថែទាំ និងគោលគំនិតរួមមួយដែលបង្រួបបង្រួមគិលានុបដ្ឋាកទាំងឡាយ[3] នៅទូទាំងពិភពលោក ។

ដំណើរការថែទាំ ដែលត្រូវប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា មានធាតុគន្លឹះចំនួន៥៖

- ការប៉ាន់ប្រមាណស្ថានភាពសុខភាព
- ការធ្វើរោគវិនិច្ឆ័យថែទាំ
- ការធ្វើផែនការថែទាំ

---

[1] .Cambodia Ministry of Health Hospital Services Department. 2012. Manual of Nursing Process
[2] .Orlando, I.J. 1972 គោលការណ៍ណែនាំ )Discipline) និងការបង្រៀនអំពីដំណើរការថែទាំ G.P. Putnam's Sons .
[3] :American Nurses Association. The Nursing Process. Available from http://www.nursingworld.org/EspeciallyForYou/What-is-Nursing/Tools-You-Need/Thenursingprocess.html

- ការអនុវត្តការថែទាំ និង
- ការវាយតម្លៃ និងកែសម្រួលការថែទាំ ប្រសិនបើចាំបាច់

## ១.៤ បរិបទនៃការថែទាំ

ការថែទាំ គឺជាសិល្បៈ និងជាវិទ្យាសាស្ត្រដែលកំណត់លក្ខណៈដោយការឆ្លុះបញ្ចាំង និងការគិតត្រិះរិះពិចារណា និងការគ្របដណ្តប់លើការថែទាំដែលត្រូវបានផ្តល់ជូន តាមរយៈការអនុវត្តដែលមានលក្ខណៈស្វយ័ត និងសហការដោយផ្តោតលើបុគ្គល គ្រួសារ ក្រុមមនុស្ស និងសហគមន៍ នៅគ្រប់ស្ថានភាពទាំងអស់ ដោយមិនគិតអំពីអាយុ វប្បធម៌ ជាតិសាសន៍ ឬសាសនាអ្វីឡើយ។ នៅក្នុង បរិបទនេះ ការថែទាំ រួមបញ្ចូលការពង្រឹងលើកកម្ពស់សុខភាព ការបង្ការសុខភាពមិនល្អ ការថែទាំអ្នកជំងឺ ការស្តារនីតិសម្បទា ការថែទាំមនុស្សដែលមានពិការភាពនិងតម្រូវការពិសេស និងការថែទាំមនុស្សដែលជិតស្លាប់។

គិលានុបដ្ឋាក ត្រូវបានទទួលស្គាល់ថាជាអ្នកប្រកបវិជ្ជាជីវៈដែលមានទំនួលខុសត្រូវនិងគណនេយ្យភាព ដែលបំពេញការងារក្នុងភាពជាដៃគូជាមួយអតិថិជន គ្រួសារ និងសហគមន៍ និងដោយធ្វើសហប្រតិបត្តិការជាមួយអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀត ដើម្បីផ្តល់ជំនួយគាំទ្រផ្នែកសុខាភិបាល ការថែទាំ និងជំបូន្មាន ដែលរួមបញ្ចូលវិធានការបង្ការជំងឺ ការស្វែងរកតាមដានជំងឺ ការទទួលបានការថែទាំ ឬជំនួយសមស្របដទៃទៀត (ប្រសិនបើចាំបាច់) និងការអនុវត្តវិធានការសង្គ្រោះបន្ទាន់។ គិលានុបដ្ឋាក មានតួនាទីសំខាន់ក្នុងការផ្តល់ការប្រឹក្សាយោបល់ និងការអប់រំផ្នែកសុខាភិបាល ជាមួយនឹងបុគ្គល គ្រួសារ និងសហគមន៍។ អតិថិជនទទួលខុសត្រូវចំពោះសុខភាពផ្ទាល់ខ្លួនរបស់ពួកគេ ហើយគិលានុបដ្ឋាកត្រូវគោរពអតិថិជនក្នុងនាមជាដៃគូក្នុងការផ្តល់ការថែទាំ។ គិលានុបដ្ឋាក ផ្តល់ជូនការថែទាំដែលយកចិត្តទុកដាក់ចំពោះអតិថិជនជាចម្បង ដោយអនុវត្តតាមរបៀបនៃការថែទាំ និងគោរពតាមនិយាមវិជ្ជាជីវៈអនុវត្ត ក្រមប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈ។

ការថែទាំ គឺជាវិជ្ជាជីវៈដែលផ្អែកលើគោលការណ៍ច្បាប់និងក្រមសីលធម៌ និងរួមបញ្ចូលភាពជាអ្នកដឹកនាំ ការបង្ហាត់ណែនាំ ការគ្រប់គ្រងត្រួតពិនិត្យ ការតស៊ូមតិ ការសិក្សាស្រាវជ្រាវ ការអប់រំ ការគ្រប់គ្រង ការចូលរួមក្នុងការបង្កើតគោលនយោបាយ និងការលើកកម្ពស់បរិយាកាសដែលមានសុវត្ថិភាព។

គិលានុបដ្ឋាកដែលបានចុះបញ្ជិកា និងអជ្ញាបណ្ណប្រកបវិជ្ជាជីវៈមានសុពលភាពចេញដោយគណៈគិលានុបដ្ឋាកកម្ពុជា ជាគិលានុបដ្ឋាកដែលមានសមត្ថភាពក្នុងការផ្តល់ការថែទាំនៅគ្រឹះស្ថានព្យាបាល និងថែទាំសុខភាពដូចជា មន្ទីរពេទ្យជាតិ មណ្ឌលមណ្ឌលជាតិ មន្ទីរពេទ្យខេត្ត មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព មន្ទីរពេទ្យក្រោមក្រសួងការពារជាតិ មណ្ឌលសុខភាពក្រោមក្រសួងការងារ និងអតីតយុទ្ធជន (រោកចក្រ) សេវាឯកជន (មន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល និងសេវាសម្រាកព្យាបាលឯកជនផ្សេងៗទៀត ព្រមទាំងបន្ទប់ថែទាំឯកជន) ការថែទាំនៅតាមផ្ទះ ឬមណ្ឌលថែទាំមនុស្សចាស់។

គិលានុបដ្ឋាកដែលបានចុះបញ្ជិកា អាចធ្វើការសិក្សាក្រោយបរិញ្ញាបត្របន្ថែមនៅក្នុងផ្នែកឯកទេសនៃការអនុវត្តថែទាំ (ឧទាហរណ៍ គិលានុបដ្ឋាកដាក់ថ្នាំសណ្តំ គិលានុបដ្ឋាកឯកទេសសុខភាពផ្លូវចិត្ត គិលានុបដ្ឋាកឯកទេសជំងឺភ្នែក គិលានុបដ្ឋាកឯកទេសជំងឺកុមារ ការគិលានុបដ្ឋាកថែទាំជំងឺធ្ងន់ជាដើម)។

កម្មវិធីសិក្សាគិលានុបដ្ឋាក ធ្វើឱ្យគិលានុបដ្ឋាកដែលត្រូវបានចុះបញ្ជិកា មានការត្រៀមខ្លួនបានល្អក្នុងការផ្តល់ការថែទាំប្រកបដោយគុណភាព សន្តិនិយម និងមេត្តាធម៌ ជូនដល់បុគ្គល គ្រួសារ និងក្រុមមនុស្សនានា ដើម្បីលើក

កម្ពស់និងថែរក្សាសុខភាពល្អរបស់អតិថិជន និងផ្ដល់ជំនួយក្នុងការជាសះស្បើយឡើងវិញ ឬការសម្របខ្លួនទៅគ្រប់កម្រិតបម្រែបម្រួលជាបន្តបន្ទាប់នៃស្ថានភាពសុខភាពនិងជំងឺ ហើយផ្ដល់ជាសុកភាព និងរក្សាបាននូវសេចក្ដីថ្លៃថ្នូរនៅពេលវេលាចុងក្រោយនៃជីវិត និងនៅពេលស្លាប់។

វិជ្ជាជីវៈគិលានុបដ្ឋាក ប្ដេជ្ញាចិត្តធ្វើការអភិវឌ្ឍចំណេះដឹងថ្មី និងទ្រឹស្ដីថ្មីៗតាមរយៈការអប់រំ ការអង្កេត និងការសិក្សាស្រាវជ្រាវជាបន្ត។

## ១.៥ គោលការណ៍ណែនាំសម្រាប់ការអនុវត្តការថែទាំ

1. <u>ការថែទាំដែលមានគុណភាព</u>៖ គិលានុបដ្ឋាកផ្ដល់ការថែទាំ ដោយប្រើប្រាស់វិធីសាស្ត្រកែលម្អគុណភាពឱ្យប្រសើរឡើង ដើម្បីផ្ដល់ការថែទាំដ៏ល្អបំផុតតាមដែលអាចធ្វើបាន។
2. <u>ការសិក្សារៀនសូត្របន្ត</u>៖ គិលានុបដ្ឋាក ប្ដេជ្ញាចិត្តធ្វើការសិក្សារៀនសូត្របន្ត។ ការផ្លាស់ប្ដូរឥតឈប់ឈរនៃតម្រូវការផ្នែកសុខភាពរបស់ប្រជាជន បច្ចេកវិទ្យាថ្មីៗ ការព្យាបាលនិងឱសថថ្មីៗ និងការលេចឡើងនូវជំងឺថ្មីៗ តម្រូវឱ្យគិលានុបដ្ឋាកដែលបានចុះបញ្ជិកា បង្កើនការយល់ដឹងរបស់ពួកគេនិងធ្វើបច្ចុប្បន្នភាពជំនាញរបស់ពួកគេជាប្រចាំ។
3. <u>ការអនុវត្តដោយផ្អែកលើភស្តុតាង</u>៖ គិលានុបដ្ឋាក ប្រើប្រាស់ការគិតត្រិះរិះ ការគិតឆ្លុះបញ្ចាំងការអង្កេត និងទិន្នន័យសិក្សាស្រាវជ្រាវ នៅពេលធ្វើការសម្រេចចិត្តអំពីការថែទាំ ដើម្បីឱ្យការថែទាំត្រូវបានផ្ដល់ដោយផ្អែកលើភស្តុតាងល្អបំផុតដែលមាន។
4. <u>ស្វ័យភាពវិជ្ជាជីវៈ</u>៖ គិលានុបដ្ឋាក មានសមត្ថភាពអាចធ្វើការសម្រេចចិត្តលើការថែទាំ និងមានសេរីភាពធ្វើសកម្មភាពដោយស្វ័យភាពក្នុងការផ្ដល់ការថែទាំ ស្របតាមចំណេះដឹងវិជ្ជាជីវៈ សមត្ថភាព សិទ្ធិអំណាចផ្លូវច្បាប់ និយាមវិជ្ជាជីវៈនៃការថែទាំ និងការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈ។
5. <u>សមាជិកក្រុម</u>៖ គិលានុបដ្ឋាក បំពេញតួនាទីជាផ្នែកមួយនៃក្រុមអ្នកថែទាំសុខភាព និងសហការជាមួយអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធដទៃទៀត ក្នុងការផ្ដល់ការថែទាំនៅក្នុងព្រំដែននៃការត្រៀមរៀបចំខ្លួនផ្នែកវិជ្ជាជីវៈ និយាមវិជ្ជាជីវៈនៃការអនុវត្ត និងនិយាមវិជ្ជាជីវៈនៃការអនុវត្ត។
6. <u>អ្នកតស៊ូមតិសម្រាប់អតិថិជន</u>៖ គិលានុបដ្ឋាក គឺជាអ្នកតស៊ូមតិសម្រាប់អតិថិជន ក្នុងការផ្ដល់ជូននូវការថែទាំសុខភាពប្រកបដោយសមធម៌ បរិយាកាសថែទាំសុខភាពដែលមានសុវត្ថិភាព និងការផ្ដល់ការថែទាំដែលមានគុណភាព។

## ១.៦.គោលបំណងនៃនិយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាក

គោលបំណងនៃនិយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាករួមមាន៖

- ដើម្បីបំពេញតាមកាតព្វកិច្ចផ្លូវច្បាប់ និងការទទួលខុសត្រូវវិជ្ជាជីវៈរបស់ គ.គិ.ក នៅក្នុងការការពារសាធារណជនពីការប្រកបវិជ្ជាជីវៈដោយគ្មានក្រមសីលធម៌ឬអសមត្ថភាព ដោយការគ្រប់គ្រងលើការអប់រំនិងការប្រកបវិជ្ជាជីវៈថែទាំ។
- ដើម្បីគូសបញ្ជាក់ឱ្យបានច្បាស់ចំពោះគិលានុបដ្ឋាកដែលបានចុះបញ្ជិកាទាំងអស់ អតិថិជននិងគ្រួសាររបស់ពួកគេ សហគមន៍ និងភាគីពាក់ព័ន្ធដទៃទៀតកម្រិតនៃការថែទាំអប្បបរមាដែលអាចទទួលយកបានសម្រាប់ការអនុវត្តការថែទាំប្រកប ដោយសុវត្ថិភាពនិងសមត្ថភាព។
- ដើម្បីធ្វើជាលិខិតុបករណ៍សម្រាប់ការត្រួតពិនិត្យនិងការវាយតម្លៃលើការអនុវត្តការថែទាំ និងការអនុវត្តរបស់គិលានុបដ្ឋាកនីមួយៗ។



Sm

- ដើម្បីផ្តល់ការណែនាំនៅក្នុងការបង្កើតកម្មវិធីសិក្សាថែទាំ និងការរៀបចំនិស្សិត គិលានុបដ្ឋាកសម្រាប់ ការប្រកបវិជ្ជាជីវៈ។
- ដើម្បីប្រើប្រាស់ជាក្របខណ្ឌសម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈបន្ត។

និយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាកទាំងនេះផ្តល់ជូនក្របខណ្ឌសម្រាប់វាយតម្លៃ ការអនុវត្តរបស់គិលានុបដ្ឋាក ដើម្បីធានាថាវាមានសុវត្ថិភាព និងស្របតាម និយាមវិជ្ជាជីវៈអនុវត្តដែលបានតម្រូវលើការវិទ្យាសាស្ត្រថែទាំនៅក្នុងប្រទេសកម្ពុជា។ និយាមវិជ្ជាជីវៈនៅក្នុងឯកសារនេះ អនុវត្តចំពោះរាល់គិលានុបដ្ឋាកដែលបានចុះបញ្ជិកា និងទទួលបានអាជ្ញាបណ្ណពី គណៈគិលានុបដ្ឋាកកម្ពុជានៅគ្រប់ ទីកន្លែងទាំងអស់ដែលគិលានុបដ្ឋាកធ្វើការងារ។

# ផ្នែកទី២៖ និយាមវិជ្ជាជីវៈនៃការអនុវត្តសម្រាប់គិលានុបដ្ឋាក

## ២ ១.និយាមវិជ្ជាជីវៈនៃការអនុវត្តគ្លីនិកដែលមានប្រសិទ្ធភាព

### ២.១.១ និយាមនៃការអនុវត្តគ្លីនិក

និយាមវិជ្ជាជីវៈទី១

គិលានុបដ្ឋាក ត្រូវផ្តល់ការថែទាំក្នុងដែនកំណត់នៃចំណេះដឹង ជំនាញ និងបទពិសោធន៍និងនិយាមវិជ្ជាជីវៈនៃការអនុវត្តរបស់ពួកគេ ហើយតាមរយៈការប្រើប្រាស់របៀបនៃការថែទាំនេះ ត្រូវប្រើប្រាស់ការវិនិច្ឆ័យតាមបែបវិជ្ជាជីវៈ និងការគិតត្រិះរិះពិចារណានៅក្នុងការផ្តល់ជូនរាល់ការថែទាំទាំងអស់។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ ធ្វើការប៉ាន់ប្រមាណ ជាលក្ខណៈប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយទៅលើអតិថិជន ដោយការពិចារណាទៅលើកត្តាវប្បធម៌និងសេដ្ឋកិច្ច ការសិក្សា អង្កេតជាប្រចាំ ការប្រមូលគំរូសំណាកសំខាន់ៗ ការប្រាស្រ័យទាក់ទង និងការរៀបចំចងក្រងឯកសារលទ្ធផលប៉ាន់ប្រមាណ និងការបញ្ជូនបន្តអតិថិជនដែលមានតម្រូវការថែទាំស្មុគស្មាញ។<br>▪ ប្រើប្រាស់ការវិនិច្ឆ័យបែបវិជ្ជាជីវៈ ដើម្បីធ្វើផែនការ អនុវត្ត និងត្រួតពិនិត្យ រាល់ការថែទាំទាំងអស់ នៅក្នុងកិច្ចពិគ្រោះយោបល់ជាមួយអតិថិជននិងក្រុមអ្នកថែទាំ។ | ▪ ប្រើប្រាស់ការគិតត្រិះរិះនៅក្នុងការប្រើប្រាស់របៀបនៃការថែទាំ ដើម្បីវាយតម្លៃតម្រូវការថែទាំសុខភាពរបស់អតិថិជន ធ្វើរោគវិនិច្ឆ័យថែទាំយ៉ាងសុក្រិត និងផ្តល់អាទិភាពដល់ការថែទាំដែលត្រូវផ្តល់ជូន ធ្វើផែនការ និងអនុវត្តយុទ្ធសាស្ត្រថែទាំសមស្រប ត្រួតពិនិត្យវឌ្ឍនភាពនៃការថែទាំ ធ្វើការកែតម្រូវចាំបាច់នានាចំពោះការថែទាំ និងវាយតម្លៃលទ្ធផល។<br>▪ គាំទ្រនិងគ្រប់គ្រងគិលានុបដ្ឋាកបឋមនៅក្នុងការប្រើប្រាស់របៀបនៃការថែទាំ និងការផ្តល់ការថែទាំ។ | ▪ ផ្តល់ភាពជាអ្នកដឹកនាំផ្នែកគ្លីនិកដល់ក្រុមអ្នកថែទាំ ដោយផ្អែកលើចំណេះដឹង និងការយល់ដឹងអំពីទ្រឹស្តីថែទាំ និងទ្រឹស្តីសង្គមដែលពាក់ព័ន្ធ និងក្របខណ្ឌនានា នៅពេលប្រើប្រាស់ចំពោះការផ្តល់ការថែទាំវិជ្ជាជីវៈគិលានុបដ្ឋាក។<br>▪ គាំទ្រ និងគ្រប់គ្រងគិលានុបដ្ឋាកបឋម និងបរិញ្ញាបត្ររងគិលានុប-ដ្ឋាក នៅក្នុងការផ្តល់ការថែទាំផ្នែកគ្លីនិកនិងការអនុវត្តរបៀបនៃការថែទាំ ដោយធ្វើសកម្មភាពជាទីភ្នាក់ងារអភិបាលផ្លាស់ប្តូរនិងដែលជាគំរូតួនាទីនៃផ្នែកគ្លីនិក។<br>▪ វាយតម្លៃផែនការថែទាំដើម្បីធានាថាផែនការនេះ ឆ្លុះបញ្ចាំងនូវវិធី |

| | | |
|---|---|---|
| ▪ ផ្តល់រាល់ការថែទាំនៅក្នុងព្រំដែនវិជ្ជាជីវៈនៃចំណេះដឹង ជំនាញ និងបទពិសោធន៍ផ្ទាល់ខ្លួន។ | ▪ ផ្តល់ការថែទាំដោយផ្ទាល់ដល់អតិថិជនដែលមានតម្រូវការថែទាំចាំបាច់។ | សាស្ត្រថែទាំ និងផ្អែកលើភស្តុតាងដែលមានប្រសិទ្ធភាពដើម្បីបំពេញតាមតម្រូវការរបស់អតិថិជន និងសម្រេចគោលដៅថែទាំ។ |
| គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ ផ្តល់ដំបូន្មាននិងការណែនាំគ្លីនិកជំនាញដល់ក្រុមអ្នកថែទាំសុខភាព ក្នុងការអនុវត្តគ្រប់ដំណាក់កាលទាំងអស់នៃរបៀបថែទាំដែលទាក់ទងនឹងការថែទាំក្នុងផ្នែកឯកទេស។<br>▪ ប្រើប្រាស់ជំនាញឯកទេសក្នុងការជួយសម្រួលក្នុងការប៉ាន់ប្រមាណ និងតាមដានលើកិច្ចការថែទាំជាប់ជាបន្ត និងអនុវត្តតាមជំនាញឯកទេសរបស់ខ្លួនដើម្បីជួយឱ្យស្ថានភាពសុខភាពរបស់អ្នកជំងឺបានប្រសើរឡើងវិញ។ | | |
| គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ វាយតម្លៃពាក់ព័ន្ធនឹងការអនុវត្តការថែទាំ និងផ្តួចផ្តើមគំនិតនៃសកម្មភាពកែតម្រូវ ប្រសិនបើចាំបាច់។ | | |
| គិលានុបដ្ឋាកបណ្ឌិត<br>▪ ផ្តល់ដំបូន្មានពីជំនាញនិងធាតុចូលទៅក្នុងគោលនយោបាយថ្នាក់ជាតិ និងសម្របសម្រួលដល់ការអនុវត្តយ៉ាងមានប្រសិទ្ធិភាពអំពីរបៀបនៃការថែទាំចំពោះកិច្ចការថែទាំ និងសេវាថែទាំនានា។<br>▪ ផ្តល់ការអនុវត្តគ្លីនិកស្វយ័តបែបទំនើប ប្រសិនបើកំពុងធ្វើការងារនៅក្នុងផ្នែកគ្លីនិក រួមមានការធ្វើរោគ-វិនិច្ឆ័យថែទាំ និងការផ្តល់កិច្ចការថែទាំដល់អតិថិជនដែលមានតម្រូវការថែទាំស្មុគស្មាញនិងចម្រុះជាបន្តបន្ទាប់។ | | |

និយាមវិជ្ជាជីវៈទី២

គិលានុបដ្ឋាក ត្រូវផ្តល់រាល់ការថែទាំទាំងអស់ស្របតាមគោលនយោបាយ ពិធីសារ និងការណែនាំថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ នៅពេលសុខភាពរបស់អតិថិជនឬតម្រូវការថែទាំ ហួសពីដែនកំណត់វិជ្ជាជីវៈនៃការអនុវត្តរបស់គិលានុបដ្ឋាក ត្រូវពិគ្រោះយោបល់និងបញ្ជូនបន្តទៅកាន់គិលានុបដ្ឋាកដែលមានកម្រិតខ្ពស់ជាង ឬអ្នកជំនាញវិជ្ជាជីវៈសុខាភិបាល ឬសេវាកម្មដទៃទៀតតាមសមស្រប។

*សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ*

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ ផ្តល់រាល់ការថែទាំទាំងអស់ស្របតាមគោលនយោបាយ ពិធីសារ និងការណែនាំថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន<br>▪ បញ្ជូនអតិថិជន ទៅគិលានុបដ្ឋាកដែលមានជំនាញខ្ពស់ជាង ឬអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀតសម្រាប់ការប៉ាន់ប្រមាណ និងការគ្រប់គ្រងបន្ថែមទៀត ដែលអតិថិជន | ▪ ត្រួតពិនិត្យការផ្តល់ជូនកិច្ចការថែទាំនៅក្នុងផ្នែកនៃការទទួលខុសត្រូវដែលបំពេញតាមរាល់ច្បាប់និងបទបញ្ញត្តិដែលពាក់ព័ន្ធគោលនយោបាយ ពិធីសារ និងការណែនាំថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ | ▪ វាយតម្លៃប្រសិទ្ធភាព ភាពអាចប្រើប្រាស់បាន និងភាពអាចទទួលយកបាននៃការថែទាំនៅក្នុងផ្នែកនៃការទទួលខុសត្រូវ និងផ្តល់អនុសាសន៍សម្រាប់ការផ្លាស់ប្តូរ ប្រសិនបើមានតម្រូវការចាំបាច់ដើម្បីលើកកម្ពស់ការថែទាំដែលមានគុណភាព។ |

| | | |
|---|---|---|
| នោះ តម្រូវឱ្យមានការថែទាំនៅក្រៅដែនកំណត់វិជ្ជាជីវៈនៃការថែទាំដោយផ្ទាល់ ឬក្នុងករណីមិនមានវឌ្ឍនភាពតាមការរំពឹងទុក ឬក្នុងករណីមិនបានបំពេញតាមនិយាមវិជ្ជាជីវៈ និងលទ្ធផលតាមការរំពឹងទុក ឬក្នុងករណីកត់សម្គាល់ឃើញមានកត្តាហានិភ័យនានា។ | ▪ បញ្ជូនអតិថិជនបន្តទៅគិលានុបដ្ឋាកបរិញ្ញាបត្រឬអ្នកជំនាញវិជ្ជាជីវៈសុខាភិបាល ដែលតម្រូវការសុខភាព និងការថែទាំរបស់អតិថិជនទាំងនោះលើសពីសមត្ថភាពឬដែនកំណត់វិជ្ជាជីវៈនៃការអនុវត្តរបស់ក្រុមអ្នកថែទាំ។ | ▪ គ្រប់គ្រង គាំទ្រ និងណែនាំដល់គិលានុបដ្ឋាកបឋម និងបរិញ្ញាបត្ររងគិលានុបដ្ឋាក នៅក្នុងការផ្តល់រាល់ការថែទាំទាំងអស់ និងផ្តល់ការអន្តរាគមន៍ដែលសមស្របប្រសិនបើមានតម្រូវការចាំបាច់។ |
| គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ ចូលរួមបង្កើតនិងវាយតម្លៃគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំដើម្បីធានាថាខ្លឹមសារទាំងនោះ នឹងគាំទ្រដល់ការអនុវត្តការថែទាំឯកទេស និងផ្តល់អនុសាសន៍សម្រាប់ការផ្លាស់ប្តូរនានាចំពោះកិច្ចការថែទាំ។<br>▪ ចូលរួមក្នុងការបង្កើតបណ្តាញក្នុងការបញ្ជូនព័ត៌មាននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់តម្រូវការថែទាំរបស់អ្នកជំងឺដែលសមស្របតាមជំនាញឯកទេសរបស់ខ្លួនដើម្បីអនុវត្តការថែទាំឱ្យមានប្រសិទ្ធិភាព។ | | |
| គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ វាយតម្លៃការថែទាំ ដែលវាអនុលោមតាមគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំថ្នាក់ជាតិ និងនៅថ្នាក់មូលដ្ឋាន ហើយចាត់វិធានការកែតម្រូវប្រសិនបើចាំបាច់។<br><br>គិលានុបដ្ឋាកបណ្ឌិត<br>▪ ត្រួតពិនិត្យជាប្រចាំលើការអនុវត្តគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំ ដើម្បីធានាថាខ្លឹមសារទាំងនោះគាំទ្រដល់ការផ្តល់ជូនការថែទាំដែលមានគុណភាពនៅគ្រប់ទីកន្លែងទាំងអស់ ផ្តល់អនុសាសន៍សម្រាប់ការផ្លាស់ប្តូរ និងដឹកនាំដំណើរការផ្លាស់ប្តូរនោះ ប្រសិនបើតម្រូវចាំបាច់។ | | |

និយាមវិជ្ជាជីវៈទី៣

គិលានុបដ្ឋាក ត្រូវផ្តល់ការថែទាំដែលគ្មានការវិនិច្ឆ័យរិះគន់ គ្មានការរើសអើង និងមានការគិតគូរដល់វប្បធម៌ ដែលផ្តោតជាសំខាន់លើការថែទាំអតិថិជន និងគាំទ្រដល់ការនិយមចង់បាននិងជំនឿរបស់អតិថិជន ប្រសិនបើការធ្វើដូច្នោះមានសុវត្ថិភាព និងមានធនធានដែលមូលដ្ឋានអាចធ្វើទៅបាន និងក្នុងករណីដែលមិនបានបំពានទៅលើច្បាប់ គោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ ផ្តល់ការថែទាំដែលមិនរើសអើងក្នុងចំណោមអតិថិជនដែលមានការគិតគូរចំពោះផ្នែកវប្បធម៌ គុណតម្លៃ | ▪ លើកកម្ពស់វប្បធម៌នៅក្នុងកន្លែងការងារដែលគ្មានការវិនិច្ឆ័យ រិះគន់ គ្មានការរើសអើង និងមាន | ▪ ផ្តល់ការអប់រំ និងគោលការណ៍ណែនាំដល់ក្រុមអ្នកថែទាំស្តីអំពីការថែទាំដែលផ្តោតជាសំខាន់ |

| | | |
|---|---|---|
| និងជំនឿរបស់អតិថិជន និងគាំទ្រដល់ការនិយមពេញចិត្តរបស់អតិថិជន ប្រសិនបើការធ្វើដូច្នោះមានសុវត្ថិភាព។ | ការគិតគូរដល់ផ្នែក វប្បធម៌ និង ដែលចាត់ទុកអតិថិជននិងការនិយមចង់បានរបស់ពួកគាត់ជាចំណុចសំខាន់នៃការថែទាំ។ | លើអតិថិជន និងវាយតម្លៃការថែទាំដែលកំពុងផ្តល់ជូន និងផ្តល់អនុសាសន៍សម្រាប់ការកែលម្អ ប្រសិនបើចាំបាច់។ |
| គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ ចូលរួមវាយតម្លៃការថែទាំទាំងអស់ដែលមានតម្រូវការថែទាំនៅក្នុងផ្នែកឯកទេស និងប្រាកដថាការអនុវត្តការថែទាំធ្វើឡើងដោយសេចក្តីគោរព មិនមានការរើសអើង និងវាយតម្លៃជាមុន ឬប្រកាន់ពូជសាសន៍វប្បធម៌។ល។ | | |
| គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ វាយតម្លៃរាល់ការថែទាំទាំងអស់ដែលកំពុងផ្តល់ជូន ដើម្បីធានាថាការថែទាំនោះគឺពោរពេញដោយការគោរព គ្មានការវិនិច្ឆ័យរិះគន់ គ្មានការរើសអើង និងសមស្របតាមវប្បធម៌ និងការចង់បានរបស់អ្នកជំងឺប្រសិនបើមានសុវត្ថិភាព។ | | |
| គិលានុបដ្ឋាកបរិញ្ញាបត្របណ្ឌិត<br>▪ ផ្តល់ការណែនាំជំនាញនិងជាតុចូលនៅកម្រិតថ្នាក់ជាតិចំពោះការត្រួតពិនិត្យលើច្បាប់ថែទាំ បទបញ្ញត្តិ ក្រមសីលធម៌ គោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំ ដើម្បីធានាថាពួកគេគាំទ្រដល់កិច្ចការថែទាំដែលមានការគោរព គ្មានការវិនិច្ឆ័យរិះគន់ គ្មានការរើសអើង និងសមស្របតាមវប្បធម៌។ | | |

និយាមវិជ្ជាជីវៈទី៤

គិលានុបដ្ឋាកត្រូវរក្សាសិទ្ធិរបស់អតិថិជន ដើម្បីផ្តល់ការយល់ព្រមដែលទទួលបានព័ត៌មានពេញលេញចំពោះការថែទាំ និងដើម្បីធ្វើការជ្រើសរើសព័ត៌មានដែលពេញលេញអំពីការថែទាំ ដោយគាំទ្រជម្រើសនោះ ប្រសិនបើអាចធ្វើបាន និងមានសុវត្ថិភាពក្នុងការធ្វើដូច្នោះនៅក្នុងស្ថានភាព និងធនធានក្នុងមូលដ្ឋាន និងប្រសិនបើវាមិនបំពានលើច្បាប់គោលនយោបាយ ពិធីសារ ឬគោលការណែនាំថ្នាក់ជាតិ ឬ ថ្នាក់មូលដ្ឋាននោះទេ។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ ផ្តល់ដំណឹងដល់អតិថិជន និងទទួលបានការយល់ព្រម មុនពេលផ្តល់ជូនការថែទាំ។<br>▪ បញ្ជូនបន្ត ទៅគិលានុបដ្ឋាកដែលមានជំនាញខ្ពស់ជាង នូវរាល់ស្ថានភាពណាមួយដែលអតិថិជនបដិសេធមិនយល់ព្រមទទួលការថែទាំ ឬប្រសិនបើជម្រើសដែលជាការនិយមចង់បានរបស់អតិថិជន | ▪ ពង្រឹងការអនុវត្តសិទ្ធិរបស់អតិថិជននៅក្នុងការផ្តល់ជូនការយល់ព្រមដែលមានព័ត៌មានពេញលេញចំពោះការថែទាំ និងគ្រប់គ្រង និងគាំទ្រគិលានុបដ្ឋាកបឋមនៅក្នុងការទទួលបានការយល់ព្រមដែលមានព័ត៌មានពេញលេញសម្រាប់ការថែទាំទាំងអស់។<br>▪ ពិនិត្យតាមដានលើគិលានុបដ្ឋាកបឋម ក្នុងករណីជម្រើសដែល | ▪ វាយតម្លៃលើកិច្ចការថែទាំ នៅក្នុងកន្លែងការងារ ដើម្បីឱ្យប្រាកដថា អ្នកជំងឺបានយល់ព្រម មុននឹងគិលានុបដ្ឋាកផ្តល់ការថែទាំ។ |

| | | |
|---|---|---|
| សម្រាប់ការថែទាំ មិនត្រូវបានចាត់ទុកថាមានសុវត្ថិភាពនោះទេ។ | ជាការនិយមចង់បានរបស់អតិថិជនសម្រាប់ការថែទាំ មិនត្រូវបានចាត់ទុកថាមានសុវត្ថិភាព និងពង្រឹងការអនុវត្តតម្រូវការសម្រាប់ការថែទាំ ដែលមានសុវត្ថិភាព ដោយគោរពចំពោះសិទ្ធិរបស់អតិថិជនក្នុងការជ្រើសយកជម្រើសដែលទទួលបានព័ត៌មានពេញលេញអំពីការថែទាំរបស់ពួកគាត់។ | |

| |
|---|
| គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ ផ្តល់ការអប់រំនិងគោលការណ៍ណែនាំដល់ក្រុមអ្នកថែទាំ ដើម្បីធានាថាអតិថិជនដែលមានតម្រូវការថែទាំនៅក្នុងផ្នែកឯកទេសនៃការអនុវត្តការថែទាំ ដោយមានការយល់ព្រមដែលមានព័ត៌មានពេញលេញចំពោះការថែទាំរបស់ពួកគាត់ និងទទួលបានឱកាសក្នុងការជ្រើសរើសការថែទាំដែលមានព័ត៌មានពេញលេញអំពីការថែទាំរបស់ពួកគាត់។ |
| គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>• វាយតម្លៃការថែទាំដែលត្រូវបានផ្តល់ ដើម្បីធានាថាអតិថិជនបានផ្តល់ការយល់ព្រម ចំពោះការថែទាំរបស់ពួកគេ និងត្រូវបានផ្តល់ឱកាសឱ្យធ្វើការសម្រេចចិត្តដើម្បីជ្រើសរើសការថែទាំដែលពួកគេចង់បាន។ |
| គិលានុបដ្ឋាកបណ្ឌិត<br>▪ ផ្តល់ការណែនាំជំនាញ និងជាតុចូលនៅកម្រិតថ្នាក់ជាតិចំពោះការត្រួតពិនិត្យលើច្បាប់ថែទាំ បទបញ្ញត្តិ ក្រមសីលធម៌ គោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំ ដើម្បីធានាថាខ្លឹមសារទាំងនោះជួយពង្រឹងដល់ ការអនុវត្តគោលការណ៍នៃការយល់ព្រមដែលមានព័ត៌មានពេញលេញសម្រាប់កិច្ចការថែទាំទាំងអស់ និងសម្របសម្រួលដែលជាជម្រើសសម្រាប់អតិថិជននៅក្នុងការផ្តល់ជូនការថែទាំ។ |

និយាមវិជ្ជាជីវៈទី៥

គិលានុបដ្ឋាកត្រូវរក្សាការសម្ងាត់រាល់ព័ត៌មានផ្ទាល់ខ្លួនទាំងអស់ដែលទទួលបានក្នុងនាមជាអ្នកជំនាញវិជ្ជាជីវៈ និងត្រូវផ្សព្វផ្សាយតែព័ត៌មានសុខភាពទាំងឡាយណាដែលពាក់ព័ន្ធនឹងអតិថិជនទៅដល់ដៃគូរបស់ពួកគាត់ គ្រួសារឬអ្នកតំណាងផ្នែកច្បាប់ដែលមានការយល់ព្រមរបស់អតិថិជន ឬនៅពេលមានតម្រូវការផ្លូវច្បាប់នៅក្នុងការអនុវត្តតែប៉ុណ្ណោះ។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ រក្សាការសម្ងាត់របស់អតិថិជន ចែករំលែកព័ត៌មានពាក់ព័ន្ធ ទៅដល់អតិថិជនទៅតាមការ ចាំបាច់ | ▪ ពង្រឹងការរក្សាការសម្ងាត់របស់អតិថិជននៅកន្លែងបម្រើការងារ និងត្រួតពិនិត្យការបំពានលើការ | ▪ វាយតម្លៃលើដំណើរការរក្សាការសម្ងាត់របស់អតិថិជននៅកន្លែងបម្រើការងារ ដោយពង្រឹងការ |

| | | |
|---|---|---|
| ត្រូវដឹង និងផ្សព្វផ្សាយតែព័ត៌មានសុខភាព ឬព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជនតែប៉ុណ្ណោះ ដោយមានការយល់ព្រមរបស់អតិថិជន ឬនៅពេលដែលតម្រូវឱ្យអនុវត្ត ។ | សម្ងាត់ និងចាត់វិធានការកែតម្រូវ។ | អនុវត្តសិទ្ធិរបស់អតិថិជនចំពោះការរក្សាការសម្ងាត់ និងដោយមានការដោះស្រាយទ្វេភាគីណាមួយពាក់ព័ន្ធ នឹងការផ្សព្វផ្សាយព័ត៌មានសម្ងាត់។ |
| គិលានុបដ្ឋាកបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ ផ្តល់ការអប់រំ និងគោលការណ៍ណែនាំដល់ក្រុមអ្នកថែទាំដើម្បីធានាថាសិទ្ធអតិថិជនទទួលបាននូវការអនុវត្តត្រឹមត្រូវ មានការថែទាំស្របតាមឯកទេស និងរក្សាការសម្ងាត់ ព្រមទាំងប្រកបដោយក្តីគោរពជូនអតិថិជន។ | | |
| គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ វាយតម្លៃការថែទាំ ដើម្បីប្រាកដថាការរក្សាការសម្ងាត់របស់អតិថិជនត្រូវបានអនុវត្ត ហើយព័ត៌មានរបស់អតិថិជនត្រូវបានចែករំលែកដោយមានយល់ព្រមរបស់អតិថិជនតែប៉ុណ្ណោះ ឬនៅពេលដែលមានការតម្រូវឱ្យធ្វើដូច្នេះដោយស្របច្បាប់។ | | |
| គិលានុបដ្ឋាកបណ្ឌិត<br>▪ ផ្តល់ការណែនាំជំនាញនិងជាតុចូលនៅកម្រិតថ្នាក់ជាតិចំពោះការត្រួតពិនិត្យលើច្បាប់ថែទាំ បទបញ្ញត្តិ ក្រមសីលធម៌ គោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំ ដើម្បីធានាថាខ្លឹមសារទាំងនោះរក្សាបាននូវសិទ្ធិរបស់អតិថិជនចំពោះភាពឯកជន សេចក្តីថ្លៃថ្នូរ និងការរក្សាការសម្ងាត់ និងធានាថាសិទ្ធិនេះត្រូវបានគោរពនៅក្នុងការអនុវត្តជាក់ស្តែង។ | | |

## និយាមវិជ្ជាជីវៈទី៦

គិលានុបដ្ឋាក ត្រូវប្រកបវិជ្ជាជីវៈនៅក្នុងដែនកំណត់វិជ្ជាជីវៈនៃការអនុវត្តថែទាំរបស់ពួកគេផ្ទាល់ ដោយបដិសេធ និងរាយការណ៍សកម្មភាពនិងការទទួលខុសត្រូវដែលបានប្រគល់ជូននៅក្រៅដែនកំណត់ជីវៈនៃការអនុវត្ត ឬមិនអាចបំពេញការងារប្រកប ដោយសុវត្ថិភាពនិងត្រឹមត្រូវតាមជំនាញហើយគួរតែបង្ហាញការវិនិច្ឆ័យ និងការទទួលខុសត្រូវប្រកបដោយវិជ្ជាជីវៈនៅពេលចាត់តាំងកិច្ចការថែទាំដល់គិលានុបដ្ឋាកឬអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀត។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ អនុវត្តក្នុងដែនកំណត់វិជ្ជាជីវៈនៃការអនុវត្តផ្ទាល់ខ្លួន និងមិនផ្តល់ការថែទាំ ឬទទួលយកសកម្មភាពឬការទទួលខុសត្រូវដែលបានប្រគល់ដែលមិនអាចអនុវត្តបាន ប្រកបដោយសុវត្ថិភាពនិងសុវត្ថិភាព ឬនៅក្រៅនិយាមវិជ្ជាជីវៈនៃការអនុវត្តផ្ទាល់ខ្លួនឡើយ។ | ▪ បង្ហាញការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ នៅពេលប្រគល់កិច្ចការថែទាំដល់គិលានុបដ្ឋាក ឬអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀតនិងត្រួតពិនិត្យមើលលទ្ធផលនៃការថែទាំដែលបានប្រគល់។<br>▪ បញ្ជូនបន្តទៅ គិលានុបដ្ឋាកបរិញ្ញាបត្រ ឬអ្នកជំនាញវិជ្ជាជីវៈ | ▪ ត្រួតពិនិត្យការថែទាំតម្រូវចាំបាច់ដែលស្ថិតនៅក្នុងដែនកំណត់វិជ្ជាជីវៈនៃការអនុវត្តរបស់គិលានុបដ្ឋាក និងឆ្លើយតបយ៉ាងសមស្របទៅនឹងសំណើសុំការថែទាំណាមួយដែលស្ថិតនៅក្រៅវិសាលភាពនៃការអនុវត្តរបស់ គិលានុបដ្ឋាក។ |

| | | |
|---|---|---|
| | សុខាភិបាលផ្សេងទៀតក្នុងករណីតម្រូវការថែទាំណា ដែលនៅក្រៅ ដែនកំណត់នៃការអនុវត្តវិជ្ជាជីវៈរបស់ គិលានុបដ្ឋាកបឋម និងគិលានុបដ្ឋាកបរិញ្ញាបត្ររង។ | ▪ វាយតម្លៃការប្រគល់កិច្ចការថែទាំ ដែលការប្រគល់ភារកិច្ចនោះ មានសុវត្ថិភាព និងសមស្រប ហើយលទ្ធផលនៃការថែទាំដែលបានប្រគល់នោះ មានលក្ខណៈល្អគ្រប់គ្រាន់។ |
| គិលានុបដ្ឋាកបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ ត្រួតពិនិត្យការថែទាំដែលបានផ្តល់ជូនដល់អតិថិជននៅក្នុងផ្នែកឯកទេសនៃការអនុវត្តការថែទាំក្នុងការគាំទ្រ និងគ្រប់គ្រងក្រុមអ្នកថែទាំដើម្បីលើកកម្ពស់ចំណេះដឹង ជំនាញ និងសមត្ថភាពនៅក្នុងការផ្តល់ជូនការថែទាំឯកទេសដែលមានតម្រូវការចាំបាច់។ | | |
| គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ វាយតម្លៃការអនុវត្តតាមនិយាមនៃការអនុវត្តការថែទាំ និងកំណត់រកបញ្ហានៃការមិនអនុវត្តតាម ហើយចាត់វិធានការដើម្បីកែលម្អប្រសិនបើចាំបាច់។ | | |
| គិលានុបដ្ឋាកបណ្ឌិត<br>▪ ផ្តួចផ្តើមនិងចុះធ្វើការត្រួតពិនិត្យថ្នាក់ជាតិ និងត្រួតពិនិត្យវាយតម្លៃឡើងវិញលើការគោរពតាមនិយាមវិជ្ជាជីវៈនៃការអនុវត្តការថែទាំសុវត្ថិភាព និងលទ្ធផលនៃការថែទាំដែលបានប្រគល់ជូន ហើយផ្តល់អនុសាសន៍សម្រាប់ការផ្លាស់ប្តូរតាមការចាំបាច់។ | | |

និយាមវិជ្ជាជីវៈទី៧

គិលានុបដ្ឋាកត្រូវរក្សាកំណត់ត្រាសុខភាពជាលាយលក្ខណ៍អក្សរឬតាមប្រព័ន្ធឌីជីថល ឱ្យបានត្រឹមត្រូវនិងពេញលេញ ដែលចងក្រងរាល់ការថែទាំទាំងអស់ដែលបានផ្តល់ជូនឬមិនបានផ្តល់ជូនយ៉ាងច្បាស់លាស់។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ រក្សាកំណត់ត្រាសុខភាព ជាលាយលក្ខណ៍ អក្សរឬតាមប្រព័ន្ធឌីជីថលយ៉ាងត្រឹមត្រូវនិងពេញលេញ និងប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មានយ៉ាងមានប្រសិទ្ធភាព ប្រសិទ្ធផល និងសមស្របដើម្បីបញ្ចូលទិន្នន័យរបស់អតិថិជន។ | ▪ ត្រួតពិនិត្យការចងក្រងឯកសារនៃការថែទាំនិងកំណត់ត្រារបស់អតិថិជន សម្រាប់សុក្រឹតភាព ភាពងាយស្រួលអាន និងភាពទាន់ពេលវេលានៃការបញ្ចូលទិន្នន័យ ដើម្បីលើកកម្ពស់គុណភាពនិងនិរន្តរ៍ភាពនៃការថែទាំ។ | ▪ ការពង្រឹងបន្ថែមទៅលើសារៈសំខាន់ គោលបំណង និងលក្ខខណ្ឌតម្រូវផ្នែកច្បាប់ចំពោះគិលានុបដ្ឋាកបឋម និងគិលានុបដ្ឋាកបរិញ្ញាបត្ររងសម្រាប់ ការចងក្រងឯកសារនៃរាល់ការថែទាំ ទាំងអស់។ |
| គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ ចូលរួមបង្កើតនិងត្រួតពិនិត្យលើការចងក្រងឯកសារថែទាំ ទាំងជាលាយលក្ខណ៍អក្សរនិងតាមប្រព័ន្ធអេឡិចត្រូនិកនៅតាមគ្រឹះស្ថានថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនៅក្នុងផ្នែកឯកទេសនៃការអនុវត្តការថែទាំ ដែលមានភាពសុក្រឹត លម្អិត | | |

| |
|---|
| គ្រប់ជ្រុងជ្រោយ និងបំពេញរាល់លក្ខខណ្ឌតម្រូវផ្នែកច្បាប់ទាំងអស់។ |
| គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ វាយតម្លៃការកត់ត្រានៃការថែទាំ ក្នុងឯកសារអ្នកជំងឺ និងផ្តល់ការណែនាំ សកម្មភាពកែតម្រូវ ឬការផ្លាស់ប្តូរ ដើម្បីបង្កើនភាពត្រឹមត្រូវ គុណភាព ឬការអនុលោមតាមច្បាប់។ |
| គិលានុបដ្ឋាកបណ្ឌិត<br>▪ វាយតម្លៃលើការចងក្រងឯកសារថែទាំនៅកម្រិតថ្នាក់ជាតិដែលបំពេញតាមលក្ខខណ្ឌតម្រូវផ្នែកគ្លីនិក និងផ្នែកច្បាប់ និងផ្តល់អនុសាសន៍ដើម្បីកែលម្អការចងក្រងឯកសារទាំងជាលាយលក្ខណ៍អក្សរ និងតាមប្រព័ន្ធអេឡិចត្រូនិកនៅពេលមានការចាំបាច់។ |

និយាមវិជ្ជាជីវៈទី៨

គិលានុបដ្ឋាក ត្រូវគោរពគ្រប់ពេលវេលាតាមគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងនិងបង្ការការចម្លងរោគ នៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន រួមទាំងអនាម័យដៃ សុជីវធម៌ពេលក្អក ឬកណ្តាស់ និងភាពកខ្វក់ដែលបណ្តាលមកពីឈាមនិងជាតិទឹកក្នុងរាងកាយដទៃទៀត និងផ្តល់ការថែទាំដោយប្រើប្រាស់បម្រុងប្រយ័ត្នដែលមានលក្ខណៈជាសាកល ដើម្បីបង្ការការឆ្លងជំងឺទៅវិញទៅមកក្នុងចំណោមអតិជននិងគិលានុបដ្ឋាក។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ ធ្វើបច្ចុប្បន្នភាពចំណេះដឹង និងជំនាញក្នុងការប្រើប្រាស់ឧបករណ៍ការពារខ្លួន រួមមានបច្ចេកទេសត្រឹមត្រូវនៅក្នុងការពាក់ឬដោះឧបករណ៍ការពារខ្លួនឱ្យបាន ត្រឹមត្រូវ។<br>▪ គោរពគ្រប់ពេលវេលា តាមគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង និង បង្ការការចម្លងរោគនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដោយយកចិត្តទុកដាក់ជាពិសេស ទៅលើអនាម័យដៃ សុជីវធម៌ពេលក្អក ឬកណ្តាស់ និងភាពកខ្វក់ដែលបណ្តាលមកពីឈាមឬសារធាតុរាវក្នុងរាងកាយដទៃទៀត។ | ▪ គ្រប់គ្រង គាំទ្រ និងផ្តល់ការណែនាំដល់គិលានុបដ្ឋាកបឋម ស្របតាមគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំស្តីពីការគ្រប់ គ្រង និងបង្ការការចម្លងរោគ ។<br>▪ ត្រួតពិនិត្យការគោរពតាមគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងនិងបង្ការការការចម្លងរោគគោរពតាមការប្រើប្រាស់និងការដុតចោលដោយសុវត្ថិភាពនៃវត្ថុមុតស្រួច គោរពតាមការដុតចោលសំណល់ជីវសាស្ត្រនិងសំណល់បង្គ្រោះថ្នាក់ជីវសាស្ត្រនិងគោរពតាមបច្ចេកទេសត្រឹមត្រូវ | ▪ វាយតម្លៃលើការអនុវត្តនៅកន្លែងការងារនូវគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំពាក់ព័ន្ធនឹងការគ្រប់គ្រង និងការបង្ការការចម្លងរោគ ការប្រើប្រាស់ឧបករណ៍ការពារខ្លួន ការបំផ្លាញចោលសំណល់ជីវសាស្ត្រ និងសំណល់បង្គ្រោះថ្នាក់ជីវសាស្ត្រ និងផ្តល់ការអប់រំ ប្រសិនបើចាំបាច់ ឬផ្តល់ អនុសាសន៍សម្រាប់ការកែលម្អ។ |

| | | |
|---|---|---|
| ▪ ផ្តល់ការថែទាំដោយប្រើប្រាស់បម្រុងប្រយ័ត្នជាលក្ខណៈសាកលដើម្បីបង្ការការឆ្លងជំងឺទៅវិញទៅមកក្នុងចំណោម និងរវាងអតិថិជន និងគិលានុបដ្ឋាក។<br>▪ អនុវត្តតាមពិធីសារក្រោយការប្រឈមនឹងការឆ្លងជំងឺ ប្រសិនបើមានប្រឈមទៅនឹងការឆ្លងជំងឺឬរបួសដែលអាចកើតមាននៅកន្លែងការងារ។<br>▪ ប្រើប្រាស់និងដុតចោលរាល់វត្ថុមុតស្រួច និងផលិតផលសំណល់ទាំងអស់ ជាពិសេសសំណល់ជីវសាស្ត្រ ឬសំណល់ដែលបង្ករគ្រោះថ្នាក់ជីវសាស្ត្រ ប្រកបដោយសុវត្ថិភាព និងយ៉ាងតឹងរឹង ស្របតាមគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន។<br>▪ រួមចំណែកដល់ការបង្កើតបរិស្ថានស្អាតនិងមានអនាម័យ ដោយមានការយកចិត្តទុកដាក់ជាពិសេសទៅលើការសម្អាតបរិស្ថានសមស្រប ស្របតាមគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន។ | សម្រាប់ការពាក់ និងដោះឧបករណ៍ការពារខ្លួននិងផ្តល់ការអប់រំកែប្រែ ប្រសិនបើចាំបាច់។<br>▪ ត្រួតពិនិត្យបរិស្ថាន និងកំណត់ពីគ្រោះថ្នាក់បរិស្ថាន ឬការរំលោភបំពានលើការគ្រប់គ្រង និងបង្ការការចម្លងរោគ និងរាយការណ៍អំពីការរំលោភបំពានទាំងនោះ ឬចាត់វិធានការកែតម្រូវជាបន្ទាន់។ | |

គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ

- ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំស្តីពីការបង្ការ និងត្រួតពិនិត្យការចម្លងរោគ នៅក្នុងផ្នែកឯកទេសនៃការអនុវត្តការថែទាំ និងផ្តល់អនុសាសន៍សម្រាប់ការផ្លាស់ប្តូរចំពោះការចាំបាច់។

គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់

- វាយតម្លៃការអនុវត្តគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំស្តីពីការបង្ការ និងត្រួតពិនិត្យការចម្លងរោគនិងផ្តល់យោបល់ឱ្យមានការផ្លាស់ប្តូរនៅពេលមានភស្តុតាងច្បាស់លាស់ ។

គិលានុបដ្ឋាកបណ្ឌិត

- ផ្តល់ការណែនាំជំនាញ និងធាតុចូលនៅកម្រិតថ្នាក់ជាតិចំពោះគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំស្តីពីការបង្ការ និងត្រួតពិនិត្យការចម្លងរោគ ទាំងអស់ពាក់ព័ន្ធនឹងការអនុវត្តការថែទាំ និងសម្របសម្រួលដល់ការផ្សព្វផ្សាយព័ត៌មាននិងការអប់រំស្តីពីការគ្រប់គ្រងនិងបង្ការការចម្លងរោគទៅដល់បុគ្គលិកថែទាំទាំងអស់។

## និយាមវិជ្ជាជីវៈទី៩

គិលានុបដ្ឋាកត្រូវប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងយ៉ាងសមស្រប និងប្រកបដោយវិជ្ជាជីវៈ ដោយគោរពចំពោះសិទ្ធិរបស់អតិថិជន និងការរក្សាសិទ្ធិឯកជន ការសម្ងាត់ និងសុវត្ថិភាពនៃរបាយការណ៍សុខភាពអេឡិចត្រូនិករបស់អតិថិជនទាំងអស់។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងដោយសមស្របនៅក្នុងការផ្តល់ការថែទាំ និងរក្សាការសម្ងាត់របស់អតិថិជននៅគ្រប់ទម្រង់ទាំងអស់នៃទំនាក់ទំនង រួមទាំងទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ។<br>▪ ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង ដូចជាអ៊ីម៉ែល សារជាអក្សរ និងបណ្តាញសង្គមជាដើមយ៉ាងសមស្រប ប្រកបដោយវិជ្ជាជីវៈ និងមានការគោរព។<br>▪ ចូលទៅក្នុងប្រព័ន្ធអ៊ិនធឺណិត និងមូលដ្ឋានទិន្នន័យអេឡិចត្រូនិកដើម្បីទទួលបានព័ត៌មាន ក្នុងករណីចាំបាច់ និងប្រើប្រាស់ព័ត៌មានយ៉ាងស្របច្បាប់និងប្រកបដោយក្រមសីលធម៌ ដោយគោរពចំពោះកម្មសិទ្ធិបញ្ញា និងសិទ្ធិថតចម្លង។ | ▪ គាំទ្រដល់គិលានុបដ្ឋាកបឋមនៅក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងដើម្បីបញ្ចូលទិន្នន័យ អតិថិជនយ៉ាងសុក្រឹត ឬទទួលបានព័ត៌មានដែលពាក់ព័ន្ធនឹងអតិថិជនឬគ្រប់គ្រងសេវាថែទាំ។<br>▪ ត្រួតពិនិត្យការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងនៅកន្លែងការងារ ដែលការប្រើប្រាស់ ដោយអនុលោមតាមនិយាមវិជ្ជាជីវៈ គោលនយោបាយ ពិធីសារ គោលការណ៍ណែនាំថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន ពាក់ព័ន្ធនឹងសិទ្ធិឯកជន ការសម្ងាត់ និងសុវត្ថិភាពរបស់អតិថិជន។ | ▪ ប្រើប្រាស់ធនធានបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តល់ធាតុចូលទៅក្នុងគោលនយោបាយសុខាភិបាល ការអនុវត្ត ថវិកា ការសិក្សាស្រាវ ជ្រាវ និងការអប់រំដែលពាក់ព័ន្ធនឹងការថែទាំ។<br>▪ លើកកម្ពស់ការយល់ដឹង និងសម្របសម្រួលដល់ការបណ្តុះបណ្តាល គិលានុបដ្ឋាកស្តីពីបច្ចេក ទេសព័ត៌មាននិងទំនាក់ទំនងជាច្រើន និងការប្រមូលផ្តុំការប្រើប្រាស់ និងការគ្រប់គ្រងព័ត៌មាននិងទិន្នន័យដែលគាំទ្រដល់ការអនុវត្តការថែទាំ។ |

គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ

- ត្រួតពិនិត្យការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននៅក្នុងផ្នែកឯកទេសនៃការអនុវត្តការថែទាំដែលត្រូវបានប្រើប្រាស់យ៉ាងសមស្រប ដែលការប្រើប្រាស់ត្រូវរក្សាឱ្យបាននូវសិទ្ធិរបស់អតិថិជនចំពោះភាពឯកជន និងការសម្ងាត់ ហើយដែលការ

| |
|---|
| ប្រើប្រាស់នេះអនុលោមទៅតាមនិយាមវិជ្ជាជីវៈ គោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងសុវត្ថិភាពនិងសន្តិសុខក្នុងការរក្សាទិន្នន័យ។ |
| គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ វាយតម្លៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ការប្រើប្រាស់យ៉ាងសមស្រប ក្នុងការរក្សាបាននូវសិទ្ធិរបស់អតិថិជនចំពោះភាពឯកជន និងការសម្ងាត់ ហើយដែលការប្រើប្រាស់នេះអនុលោមតាមនិយាមវិជ្ជាជីវៈ គោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងសុវត្ថិភាពនិងសន្តិសុខក្នុងការរក្សាទិន្នន័យ។ |
| គិលានុបដ្ឋាកបណ្ឌិត<br>▪ ផ្តល់ការណែនាំជំនាញនិងជាតុចូលនៅកម្រិតថ្នាក់ជាតិ ពាក់ព័ន្ធនឹងការប្រើប្រាស់យ៉ាងសមស្របនិងប្រកបដោយប្រសិទ្ធភាពនូវបច្ចេកវិទ្យាព័ត៌មាននៅក្នុងការអនុវត្តការថែទាំ និងពាក់ព័ន្ធនឹងគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំថ្នាក់ជាតិដែលគ្រប់គ្រងលើការចូលនិងប្រើប្រាស់បច្ចេកវិទ្យាដោយគិលានុបដ្ឋាក។ |

និយាមវិជ្ជាជីវៈទី១០

គិលានុបដ្ឋាកត្រូវឆ្លើយតបប្រកបដោយវិជ្ជាជីវៈ និងដោយការគោរពនៅក្នុងស្ថានភាពគ្រាមានអាសន្ន ឬស្ថានភាពគ្រោះមហន្តរាយ និងរក្សាសមត្ថភាពនៅក្នុងការត្រៀមខ្លួន និងការឆ្លើយតបក្នុងគ្រាមានអាសន្ន។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ កំណត់ការសង្គ្រោះបន្ទាន់និងផ្តល់ការឆ្លើយតបដំណាក់កាលដំបូងដោយគោរពតាមគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំស្តីពីគ្រាមានអាសន្នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មុនពេលបញ្ជូនបន្តទៅកាន់គិលានុបដ្ឋាកឬអ្នកជំនាញថែទាំសុខភាពដទៃទៀត ប្រសិនបើចាំបាច់។<br>▪ ធ្វើបច្ចុប្បន្នភាពចំណេះដឹង និងជំនាញក្នុងការឆ្លើយតបចំពោះគ្រាអាសន្នឬគ្រោះមហន្តរាយផ្សេងៗ និងចូលរួមទៅក្នុងការធ្វើផែនការសម្រាប់គ្រាមានអាសន្ននិងគ្រោះមហន្តរាយនានា និងការអនុវត្តការឆ្លើយតបចំពោះគ្រាមានអាសន្នយ៉ាងសមស្រប។ | ▪ ផ្តល់ការដឹកនាំក្នុងការសង្គ្រោះបន្ទាន់ ដើម្បីការពារសុវត្ថិភាពរបស់អតិថិជន និងគ្រួសាររបស់ពួកគេ ព្រមទាំងបុគ្គលិក។<br>▪ ត្រួតពិនិត្យលើការគោរពតាមគោលនយោបាយ ពិធីសារ និងគោលការណែនាំស្តីពីការសង្គ្រោះបន្ទាន់ និងសម្របសម្រួលដល់ការបណ្តុះបណ្តាលនៅក្នុងការឆ្លើយតបទៅនឹងគ្រាមានអាសន្ន ឬគ្រោះមហន្តរាយ។<br>▪ ធ្វើបច្ចុប្បន្នភាពចំណេះដឹង និងការឆ្លើយតបក្នុងស្ថានភាពគ្រោះមហន្តរាយ និងចូលរួមក្នុងការអភិវឌ្ឍផែនការគ្រប់គ្រងគ្រោះមហន្តរាយ ដែលលើកកម្ពស់ដល់សុខភាពប្រជាជននៅក្នុង | ▪ ផ្តល់ការបណ្តុះបណ្តាលគ្រាប់តាមអនុវត្តការងារជាក់ស្តែង ដើម្បីផ្តល់លទ្ធភាពឱ្យគិលានុបដ្ឋាកអភិវឌ្ឍជំនាញក្នុងការឆ្លើយតបចំពោះគ្រាមានអាសន្ន និងវាយតម្លៃលើការឆ្លើយតបនិងលទ្ធផលនៃការសង្គ្រោះបន្ទាន់ដើម្បីកែលម្អការឆ្លើយតបនិងលទ្ធផលនាពេលអនាគត។<br>▪ ផ្តួចផ្តើមបង្កើតការបណ្តុះបណ្តាលត្រៀមខ្លួនសម្រាប់គ្រោះហន្តរាយ និងការហាត់គ្រាប់តាមការអនុវត្តជាក់ស្តែងដើម្បីរៀបចំគិលានុបដ្ឋាកឱ្យឆ្លើយតបយ៉ាងសមស្រប និងមានប្រសិទ្ធភាពដើម្បីការពារប្រជាជននៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងវាយតម្លៃលើការ |

| | | |
|---|---|---|
| | ស្ថានភាពគ្រោះមហន្តរាយ។ | ឆ្លើយតបនិងលទ្ធផលនៃគ្រោះមហន្តរាយ ដើម្បីកែលម្អការឆ្លើយតបនឹងលទ្ធផលនាពេលអនាគត។ |
| គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ ផ្តួចផ្តើមនិងចុះធ្វើសកម្មភាពប៉ាន់ប្រមាណអំពីកម្រិតហានិភ័យនៅ និងរៀនសូត្រ ជាទៀងទាត់ ដើម្បីពង្រឹងការត្រៀមខ្លួនរបស់គិលានុបដ្ឋាកក្នុងការឆ្លើយតបដោយសមស្រប និងប្រកបដោយប្រសិទ្ធភាពក្នុងអំឡុងពេលមានគ្រាអាសន្ន ហេតុការណ៍គ្រោះថ្នាក់ធំៗ ស្ថានភាពភ័យរន្ធត់ ឬគ្រោះមហន្តរាយនៅក្នុងផ្នែកឯកទេសនៃការអនុវត្តការថែទាំ។ | | |
| គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ ផ្តួចផ្តើមសកម្មភាពវាយតម្លៃហានិភ័យ និងការរៀនជាទៀងទាត់ ដើម្បីរៀបចំគិលានុបដ្ឋាក ឱ្យឆ្លើយតបបានសមស្រប និងប្រកបដោយប្រសិទ្ធភាពក្នុងអំឡុងពេលមានគ្រាអាសន្ន ឧបទ្ទវហេតុធំៗ របួស ឬគ្រោះមហន្តរាយ។ | | |
| គិលានុបដ្ឋាកបណ្ឌិត<br>▪ ផ្តល់ការណែនាំជំនាញ និងជាគុចូលជំនួសឱ្យការថែទាំនៅកម្រិតថ្នាក់ជាតិទៅក្នុងផែនការត្រៀមខ្លួនសម្រាប់គ្រាមានអាសន្ននិងគ្រោះមហន្តរាយ ដើម្បីធានាថាកិច្ចការថែទាំនិងសេវាកម្មនានា អាចផ្តល់ជូនបានយ៉ាងសមស្រប ហើយគិលានុបដ្ឋាកបានត្រៀមខ្លួនគ្រប់គ្រាន់ក្នុងការឆ្លើយតបនៅអំឡុងពេលសង្គ្រោះបន្ទាន់ ហេតុការណ៍គ្រោះថ្នាក់ធំៗ ស្ថានភាពភ័យរន្ធត់ ឬគ្រោះមហន្តរាយ។ | | |

## ២ ២.និយាមនៃការអនុវត្តជំនាញវិជ្ជាជីវៈដ៏មានប្រសិទ្ធភាព

### ២.២.១ និយាមវិជ្ជាជីវៈភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង

និយាមវិជ្ជាជីវៈទី១១

គិលានុបដ្ឋាកត្រូវតែគ្រប់គ្រងកិច្ចការថែទាំនិងសេវានានាដែលពួកគេផ្តល់ជូន និងរាល់ធនធានពាក់ព័ន្ធទាំងអស់ រួមទាំងពេលវេលាផ្ទាល់ខ្លួនរបស់ពួកគេផងដែរ ប្រកបដោយក្រមសីលធម៌ មានប្រសិទ្ធភាព មានសមត្ថភាព និងមានសុវត្ថិភាព និងបង្ហាញភាពជាអ្នកដឹកនាំនៅក្នុងការលើកកម្ពស់សេវាថែទាំប្រកបដោយគុណភាព។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ អនុវត្តការថែទាំប្រកបដោយសុវត្ថិភាពនិងមានសមត្ថភាព ដោយផ្តល់អាទិភាពលើតម្រូវការដែលមានភាពប្រកួតប្រជែងសម្រាប់ការថែទាំនិងការប្រើប្រាស់រាល់ធនធានទាំងអស់ រួមទាំងពេលវេលាផ្ទាល់ខ្លួន ប្រកបដោយក្រមសីលធម៌និងមានប្រសិទ្ធភាព។ | ▪ បង្ហាញភាពជាអ្នកដឹកនាំជាវិជ្ជមាននិងការគ្រប់គ្រងដ៏មានប្រសិទ្ធភាព នៅក្នុងការផ្តល់ជូនការថែទាំដែលមានគុណភាព និងដើរតួនាទីជាបុគ្គលគំរូនិងប្រកបដោយធនធានសម្រាប់គិលានុបដ្ឋាក និស្សិតគិលានុបដ្ឋាក និងអ្នកជំនាញវិជ្ជាជីវៈសុខា | ▪ ផ្តល់ភាពជាអ្នកដឹកនាំ និងការណែនាំវិជ្ជមាននិងការគ្រប់គ្រងដ៏មានប្រសិទ្ធភាពនៅក្នុងការផ្តល់ជូនការថែទាំដែលមានគុណភាព និងដើរតួនាទីជាបុគ្គលគំរូ និងប្រកបដោយធនធានសម្រាប់គិលានុបដ្ឋាកនិស្សិតគិលានុបដ្ឋាក និងអ្នកជំនាញវិជ្ជាជីវៈសុខាភិបាល |

| | | |
|---|---|---|
| | ភិបាលដទៃទៀត។ | ផ្សេងទៀត ស្ដីពីតួនាទីរបស់គិលានុបដ្ឋាក និងទស្សនៈវិជ្ជានៃការថែទាំ។ |
| គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ បង្ហាញពីភាពជាអ្នកដឹកនាំនៅក្នុងការផ្ដល់ជូនការថែទាំនិងសេវាដែលមានសុវត្ថិភាព ស័ក្តិសិទ្ធភាព សមត្ថភាព និងប្រសិទ្ធភាព នៅក្នុងផ្នែកការអនុវត្តការថែទាំឯកទេស។ | | |
| គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ ផ្ដល់ភាពជាអ្នកដឹកនាំ និងការគាំទ្រដល់គិលានុបដ្ឋាក ដោយប្រើចំណេះដឹង និងការយល់ដឹងអំពីការថែទាំដែលពាក់ព័ន្ធនឹងទ្រឹស្ដីសង្គម និងក្របខ័ណ្ឌគំនិត។ | | |
| គិលានុបដ្ឋាកបណ្ឌិត<br>▪ បង្ហាញភាពជាអ្នកដឹកនាំនៅក្នុងស្ថាប័នដែលពាក់ព័ន្ធចំពោះការថែទាំក្នុងវិស័យសុខាភិបាល និងធ្វើជាតំណាងឱ្យគិលានុបដ្ឋាកនិងការថែទាំនៅកម្រិតថ្នាក់ជាតិនិងថ្នាក់អន្តរជាតិដោយដើរតួនាទីជាគំរូនៃឧត្តមភាពនិងសមិទ្ធិផលនៃការថែទាំវេជ្ជសាស្ត្រ។ | | |

និយាមវិជ្ជាជីវៈទី១២

គិលានុបដ្ឋាកត្រូវរួមចំណែកដល់បរិយាកាសអនុវត្តការថែទាំដែលលើកកម្ពស់ដល់កិច្ចការថែទាំ និងសេវាកម្មប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងមានក្រមសីលធម៌ ដែលលើកកម្ពស់ដល់សុខុមាលភាពរបស់អតិថិជន និងកាត់បន្ថយជាអប្បបរមានូវហានិភ័យនៃលទ្ធផលសុខភាពអវិជ្ជមាននានា។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ ផ្ដល់កិច្ចការថែទាំប្រកបដោយការប្រុងប្រយ័ត្ននិងយកចិត្តទុកដាក់បន្ទាប់មកលើកកម្ពស់សុខុមាលភាពអតិថិជន និងកាត់បន្ថយហានិភ័យនៃលទ្ធផលសុខភាពអវិជ្ជមាន។ | ▪ លើកកម្ពស់បរិយាកាសវិជ្ជមាននៅក្នុងកន្លែងបម្រើការងារ និងគាំទ្រ ណែនាំ និងគ្រប់គ្រងគិលានុបដ្ឋាកបឋមនៅក្នុងការផ្ដល់ជូនការថែទាំដែលមានសុវត្ថិភាព ប្រសិទ្ធភាព និងមានក្រមសីលធម៌។ | ▪ ដឹកនាំ និងសម្របសម្រួលដល់ការអនុវត្តនៅក្នុងកន្លែងបម្រើការងារដែលប្រកបវិជ្ជាជីវៈ ជាវិជ្ជមានដែលលើកកម្ពស់ដល់ការថែទាំដែលមានសុវត្ថិភាព ប្រសិទ្ធភាពនិងមានក្រមសីលធម៌ ដែលជួយលើកកម្ពស់សុខុមាលភាព របស់អតិថិជន។ |
| គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ លើកកម្ពស់វប្បធម៌នៃការថែទាំនៅក្នុងផ្នែកឯកទេស ដែលរួមចំណែកដល់កន្លែងបម្រើការងារដែលប្រកបវិជ្ជាជីវៈជាវិជ្ជមាន និងផ្ដោតទៅលើការកែលម្អគុណភាពសុវត្ថិភាពអតិថិជន ការលូតលាស់ផ្នែកវិជ្ជាជីវៈ និងមោទនភាពនៅក្នុងជំនាញវិជ្ជាជីវៈថែទាំ។ | | |

គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់

- វាយតម្លៃកន្លែងថែទាំនៅ ដើម្បីឱ្យគិលានុបដ្ឋាកអនុវត្តការថែទាំប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងប្រកបដោយក្រមសីលធម៌ ក្នុងគោលបំណងលើកកម្ពស់សុខុមាលភាពអតិថិជន និងកាត់បន្ថយ ហានិភ័យនៃលទ្ធផលសុខភាពមិនល្អ។

គិលានុបដ្ឋាកបណ្ឌិត

- ផ្តល់ការណែនាំជំនាញនិងធាតុចូលនៅកម្រិតថ្នាក់ជាតិទៅលើតម្រូវការធនធានមនុស្ស ជំនាញចម្រុះ ការដាក់ពង្រាយ និងការប្រើប្រាស់នៅទូទាំងប្រទេសនិងនៅក្នុងផ្នែកជាក់លាក់នានា ហើយអភិវឌ្ឍនិងអនុវត្ត យុទ្ធសាស្រ្តសម្រាប់ការលើកកម្ពស់កន្លែងបម្រើការងារដែលប្រកបវិជ្ជាជីវៈជាវិជ្ជមាន។

## និយាមវិជ្ជាជីវៈទី១៣

គិលានុបដ្ឋាកត្រូវរួមចំណែកនៅក្នុងការអភិវឌ្ឍ ការអនុវត្ត ការត្រួតពិនិត្យ និងពិនិត្យវាយតម្លៃឡើងវិញលើគោលនយោបាយ ពិធីសារ កម្មវិធី និងការអនុវត្តដែលពាក់ព័ន្ធនឹងការថែទាំ ដើម្បីបន្តកែលម្អគុណភាពនៃការថែទាំ។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ ចូលរួមចំណែកក្នុងការគាំទ្រដល់ដំណើរការការពិនិត្យវាយតម្លៃឡើងវិញចំពោះគោលនយោបាយ កម្មវិធី និងការអនុវត្តដែលមានស្រាប់ ដែលមានឥទ្ធិពលលើការថែទាំនិងសេវានានា។ | ▪ លើកកម្ពស់ការយល់ដឹង និងត្រួតពិនិត្យការអនុវត្តឧបករណ៍ត្រួតពិនិត្យ គោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំដែលមានស្រាប់នៅក្នុងកន្លែងបម្រើការងារ ដោយកំណត់ពេលវេលាដែលគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំថ្មីៗដែលជាតម្រូវការចាំបាច់ និងដោយរួមចំណែកដល់ការអភិវឌ្ឍ។ | ▪ ផ្តល់ភាពជាអ្នកដឹកនាំនៅក្នុងការពិនិត្យវាយតម្លៃឡើងវិញចំពោះគោលនយោបាយ កម្មវិធី និងការអនុវត្តដែលមានស្រាប់ ដែលមានឥទ្ធិពលលើការថែទាំនិងសេវាកម្មនានា។<br>▪ ផ្តល់ភាពជាអ្នកដឹកនាំនៅក្នុងការអភិវឌ្ឍកម្មវិធីគោលនយោបាយ និងការអនុវត្តថ្មីៗដែលឆ្លុះបញ្ចាំងពីភាពជឿនលឿននៅក្នុងចំណេះដឹងផ្នែកថែទាំ ការសិក្សាស្រាវជ្រាវថ្មីៗ បច្ចេកទេសនិងសម្ភារៈបរិក្ខារ និងវាយតម្លៃលើប្រសិទ្ធភាពនៅក្នុងកន្លែងអនុវត្តការងារ។ |

គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ

- ផ្តួចផ្តើម និងសម្របសម្រួលការពិនិត្យវាយតម្លៃឡើងវិញ នៅតាម អំពីគោលនយោបាយ កម្មវិធី និងការអនុវត្តដែលមានស្រាប់ ដែលមានឥទ្ធិពលទៅលើការថែទាំដែលពាក់ព័ន្ធនឹងផ្នែកឯកទេសនៃការថែទាំ។
- ចូលរួមដឹកនាំការអភិវឌ្ឍគោលនយោបាយ កម្មវិធី និងការអនុវត្តថ្មីៗ ដើម្បីលើកកម្ពស់ការថែទាំនៅក្នុងផ្នែកឯកទេសនៃការអនុវត្តការថែទាំ។



San

| គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់ |
|---|
| ▪ ដឹកនាំបង្កើត និងត្រួតពិនិត្យឡើងវិញនូវគោលនយោបាយ កម្មវិធី និងការអនុវត្ត ដើម្បីធ្វើឱ្យការថែទាំប្រសើរឡើង និងបញ្ចូលការផ្លាស់ប្តូរនៅពេលមានភស្តុតាងថ្មី។ |
| គិលានុបដ្ឋាកបណ្ឌិត |
| ▪ ផ្តួចផ្តើមបង្កើត និងដឹកនាំការអភិវឌ្ឍនិងការពិនិត្យវាយតម្លៃឡើងវិញលើគោលនយោបាយនិងកម្មវិធីថ្នាក់ជាតិដែលពាក់ព័ន្ធ ចំពោះការរៀបចំឬពិនិត្យឡើងវិញ លើការផ្សព្វផ្សាយសៀវភៅគោលនយោបាយ នីតិវិធីដែលពាក់ព័ន្ធ និងអនុវត្តការថែទាំ។ |

## ២.២.២ ការអនុវត្តតាមច្បាប់ ក្រមសីលធម៌ និងវិជ្ជាជីវៈ

### និយាមវិជ្ជាជីវៈទី១៤

គិលានុបដ្ឋាកត្រូវអនុលោមតាមច្បាប់ ក្រមសីលធម៌និងនិយាមវិជ្ជាជីវៈនៃការថែទាំដែលពាក់ព័ន្ធទាំងអស់ ហើយត្រូវមានការទទួលខុសត្រូវចំពោះអតិថិជន និងសាធារណជនសម្រាប់ការថែទាំដែលមានសុវត្ថិភាព ប្រកបដោយក្រមសីលធម៌ និងប្រសិទ្ធិភាព។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ គោរព និងអនុវត្តតាមគោលនយោបាយ នីតិវិធី និងគោលការណ៍ណែនាំស្តីពីច្បាប់ និងបទបញ្ញត្តិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅក្នុងការផ្តល់ជូនការថែទាំនិងការងារនៅក្នុងដែនកំណត់វិជ្ជាជីវៈនៃការអនុវត្ត។<br>▪ រក្សាការចុះបញ្ជិកា និងអាជ្ញាបណ្ណថែទាំដើម្បីប្រកបវិជ្ជាជីវៈ និងគោរពតាមលក្ខខណ្ឌតម្រូវ នៃការទទួលបានការផ្តល់អាជ្ញាបណ្ណ និងការបន្តអាជ្ញាបណ្ណរបស់គណៈគិលានុបដ្ឋាកកម្ពុជា។ | ▪ ត្រួតពិនិត្យការថែទាំដែលបានផ្តល់ជូនធៀបទៅនឹងឧបករណ៍ត្រួតពិនិត្យ គោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន និងដែនកំណត់វិជ្ជាជីវៈនៃការអនុវត្ត វាយការណ៍ចំណុចខ្វះខាតក្នុងការថែទាំ ឬការខកខានមិនបានអនុវត្តដែលធ្វើឱ្យអតិថិជនប្រឈមនឹងហានិភ័យ សម្រាប់ការចាត់វិធានការកែតម្រូវ។ | ▪ វាយតម្លៃរាល់ការថែទាំទាំងអស់ដែលបានផ្តល់ជូន ដើម្បីធានានូវភាពស៊ីចង្វាក់គ្នាជាមួយច្បាប់ បទបញ្ញត្តិ និងគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំថ្នាក់ជាតិ។ |
| គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការអនុវត្តការថែទាំ | | |
| ▪ លើកកម្ពស់ការប្រើប្រាស់ និងការយល់ដឹងអំពីច្បាប់ និងនិយាមវិជ្ជាជីវៈនៃការថែទាំទាំងអស់ដែលពាក់ព័ន្ធនឹងការថែទាំសម្រាប់បុគ្គលិកគិលានុបដ្ឋាកនៅតាមគ្រឹះស្ថានថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ នៅក្នុងផ្នែកឯកទេសនៃការអនុវត្តការថែទាំ។ | | |



Sm

| |
|---|
| ▪ ត្រួតពិនិត្យការថែទាំដែលបានផ្តល់ជូននៅក្នុងផ្នែកឯកទេសនៃការអនុវត្តការថែទាំថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីធានានូវការគោរពតាមរាល់ច្បាប់និងនិយាមវិជ្ជាជីវៈនៃការថែទាំទាំងអស់ដែលពាក់ព័ន្ធនឹងការថែទាំ។ |
| គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ វាយតម្លៃការអនុវត្តការថែទាំ ដើម្បីធានានូវការគោរពតាមច្បាប់ ក្រម និងនិយាមវិជ្ជាជីវៈនៃការថែទាំទាំងអស់ដែលពាក់ព័ន្ធនឹងការថែទាំ។ |
| គិលានុបដ្ឋាកបណ្ឌិត<br>▪ ផ្តល់ការណែនាំជំនាញ និងចូលរួមក្នុងការពិនិត្យវាយតម្លៃឡើងវិញ និងធ្វើបច្ចុប្បន្នភាពលើឧបករណ៍ត្រួតពិនិត្យថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធនឹងការថែទាំ ដូចជាច្បាប់ ក្រមសីលសធ៌វិជ្ជាជីវៈ ការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈ ការដាក់ឱ្យអនុវត្តនូវដែនកំណត់វិជ្ជាជីវៈ និងក្របខណ្ឌអភិវឌ្ឍវិជ្ជាជីវៈបន្ត។ |

## និយាមវិជ្ជាជីវៈទី១៥

គិលានុបដ្ឋាកត្រូវប្រកបវិជ្ជាជីវៈប្រកបដោយក្រមសីលធម៌ និងធានាថា នការខកខានមិនបានអនុវត្តណាមួយចំពោះការថែទាំ ធ្វើឱ្យអតិថិជន និងក្រុមគ្រួសាររបស់ពួកគេក៏ដូចជាគិលានុបដ្ឋាកដទៃទៀតប្រឈមនឹងហានិភ័យដោយត្រូវបានកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់អវិជ្ជមានណាមួយនៃជំនឿគុណតម្លៃនិងបុរេវិនិច្ឆ័យផ្ទាល់ខ្លួនទៅលើការថែទាំ។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ គោរពអនុវត្តតាមក្រមសីលធម៌ នៅពេលផ្តល់ការថែទាំ បកស្រាយ និងអនុវត្តចំណេះដឹង ជំនាញ ការវិនិច្ឆ័យ និងឥរិយាបថដែលមាននៅក្នុងក្រមសីលធម៌ នៅពេលផ្តល់ការថែទាំ។<br>▪ អនុវត្តគោលការណ៍ក្រមសីលធម៌ ស្តីពីយុត្តិធម៌ សមធម៌ និងការគោរពចំពោះឯកជនភាព សេចក្តីថ្លៃថ្នូរ និងស្វ័យភាពរបស់អតិថិជនក្នុងការផ្តល់ការថែទាំ និងគោរពគុណតម្លៃនិងជំនឿរបស់អតិថិជន ទោះបី ជាពួកគេមានភាពខុសគ្នាពីគុណតម្លៃ និងជំនឿផ្ទាល់ខ្លួនក៏ដោយ។<br>▪ រាយការណ៍អំពីស្ថានភាពទ្វេភាគីផ្នែកក្រមសីលធម៌ដែលបានជួប | ▪ ត្រួតពិនិត្យការគោរពតាមក្រមសីលធម៌ នៅក្នុងការផ្តល់ការថែទាំ និងផ្តល់ការគាំទ្រដល់គិលានុបដ្ឋាក បឋមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តគោលការណ៍ក្រមសីល-ធម៌នៅក្នុងការផ្តល់ការថែទាំ។ | ▪ កំណត់ និងគ្រប់គ្រងបញ្ហាក្រមសីលធម៌ដែលអាចកើតមាននៅកន្លែងបម្រើការងារ ដែលឆ្លើយតបភ្លាមៗទៅនឹងរបាយការណ៍ស្តីពីក្តីកង្វល់ផ្នែកក្រមសីលធម៌ ដែលដោះស្រាយបញ្ហាទ្វេភាគីផ្នែកក្រមសីលធម៌គាំទ្រគិលានុបដ្ឋាក និងអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត នៅក្នុងស្ថានភាពស្មុគស្មាញក្នុងការអនុវត្តក្រមសីលធម៌។ |

| | | |
|---|---|---|
| ប្រទះក្នុងការផ្តល់ការថែទាំ និងស្វែងរកដំបូន្មាន និងជំនួយពីគិលានុបដ្ឋាកដទៃទៀត អំពីការឆ្លើយតបផ្នែកក្រមសីលធម៌ដ៏សមស្រប។ | | |

គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ

- ដឹកនាំការអនុវត្តក្រមសីលធម៌ និងផ្តល់ធាតុចូល និងការណែនាំដល់ក្រុមគិលានុបដ្ឋាកនៅក្នុងការធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងអតិថិជនដែលទទួលការថែទាំនៅក្នុងផ្នែកឯកទេសនៃការថែទាំ។

គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់

- ដើរតួជាធនធានមនុស្ស សម្រាប់ផ្តល់ការណែនាំដល់ក្រុមគិលានុបដ្ឋាកដើម្បីសម្រេចចិត្ត និងដោះស្រាយបញ្ហាប្រកបដោយក្រមសីលធម៌។

គិលានុបដ្ឋាកបណ្ឌិត

- កំណត់បញ្ហាក្រមសីលធម៌ដែលមានសារៈសំខាន់សម្រាប់ការថែទាំថ្នាក់ជាតិ និងផ្តល់ដំបូន្មានជំនាញនិងផ្តល់ធាតុចូលនៅក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់ការអនុវត្តក្រមសីលធម៌។

និយាមវិជ្ជាជីវៈទី១៦

គិលានុបដ្ឋាកត្រូវថែរក្សាសម្បទារាងកាយ សតិបញ្ញា និងផ្លូវចិត្តក្នុងការប្រកបវិជ្ជាជីវៈ តាមរយៈការចូលរួមយ៉ាងសកម្មនៅក្នុងយុទ្ធសាស្ត្រថែទាំខ្លួនឯង និងត្រូវចូលរួមទៅក្នុងការវាយតម្លៃការអនុវត្តការងារ ការឆ្លុះបញ្ចាំងពីខ្លួនឯង និងការពិនិត្យវាយតម្លៃឡើងវិញដោយសហការី ដើម្បីកំណត់និងដោះស្រាយបញ្ហាខ្វះចន្លោះឬនិយាមវិជ្ជាជីវៈផ្នែកវិជ្ជាជីវៈឬផ្ទាល់ខ្លួនដែលជះឥទ្ធិពលទៅលើសម្បទារាងកាយក្នុងការប្រកបវិជ្ជាជីវៈ និងការផ្តល់ការថែទាំដែលមានគុណភាព។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ ផ្តល់ការថែទាំនិងបង្ហាញឥរិយាបថទាំងផ្នែកវិជ្ជាជីវៈ និងផ្ទាល់ខ្លួន ក្នុងរបៀបមួយដែលរក្សាបាននូវសុចរិតភាពនៃវិជ្ជាជីវៈគិលានុបដ្ឋាក លើកកម្ពស់ទំនុកចិត្តរបស់សាធារណជនមកលើវិជ្ជាជីវៈនេះ និងមិនធ្វើអ្វីមួយដែលនាំឱ្យវិជ្ជាជីវៈនេះធ្លាក់ទៅក្នុងភាពអាប់អោនកេរ្តិ៍ឈ្មោះឡើយ។<br>▪ ថែរក្សាសម្បទារាងកាយ សតិបញ្ញា និងផ្លូវចិត្តក្នុងការប្រកបវិជ្ជាជីវៈ តាមរយៈការចូលរួមយ៉ាងសកម្ម | ▪ លើកកម្ពស់សុចរិតភាពនៃវិជ្ជាជីវៈគិលានុបដ្ឋាក តាមរយៈការពិភាក្សាដ៏សកម្ម និងការប្រែក្លាយខ្លួនឯងជាបុគ្គលគំរូសម្រាប់គិលានុបដ្ឋាកដទៃ។<br>▪ ត្រួតពិនិត្យសមត្ថភាព និងសម្បទាក្នុងការប្រកបវិជ្ជាជីវៈរបស់គិលា-នុបដ្ឋាកនៅក្នុងផ្នែកនៃការទទួលខុសត្រូវ ហើយផ្តួចផ្តើមវិធានការកែតម្រូវដើម្បីដោះស្រាយចំណុចខ្វះខាតដែលត្រូវ | ▪ អនុវត្តសវនកម្មលើការថែទាំជាប្រចាំដែលផ្តល់ជូននៅក្នុងកន្លែងប្រកបការងារ រួមមានការយល់ព្រមដែលមានព័ត៌មានគ្រប់គ្រាន់ ការរក្សាការសម្ងាត់ ការថែទាំប្រកបមេត្តាធម៌ និងការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់អតិថិជន ដើម្បីរក្សាបាននូវការថែទាំដែលមានគុណភាពនៅក្នុងសហគមន៍។<br>▪ ពង្រឹងនិងលើកកម្ពស់សុខភាពរាងកាយ សតិបញ្ញា និងផ្លូវចិត្ត |



Sm

| | | |
|---|---|---|
| នៅក្នុងយុទ្ធសាស្ត្រថែទាំខ្លួនឯង និងការចូលរួមនៅក្នុងការវាយតម្លៃការអនុវត្តការងារ ការឆ្លុះបញ្ចាំងពីខ្លួនឯង និងការពិនិត្យវាយតម្លៃឡើងវិញដោយសហការី ដើម្បីកំណត់និងដោះស្រាយបញ្ហាខ្វះចន្លោះផ្នែកវិជ្ជាជីវៈឬផ្ទាល់ខ្លួនដែលជះឥទ្ធិពលទៅលើការផ្តល់ការថែទាំដែលមានគុណភាព។ | បានរកឃើញ។ | តាមរយៈការពិភាក្សា និងការសិក្សារៀនសូត្រយ៉ាងសកម្ម និងការប្រែក្លាយខ្លួនជាបុគ្គលគំរូសម្រាប់គិលានុបដ្ឋាកដទៃ។ |
| **គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ**<br>▪ លើកកម្ពស់សម្បទារាងកាយ សតិបញ្ញា និងផ្លូវចិត្តក្នុងការប្រកបវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាកនៅក្នុងផ្នែកឯកទេសនៃការអនុវត្តការថែទាំ តាមរយៈការអប់រំអំពីសារៈសំខាន់នៃយុទ្ធសាស្ត្រថែទាំខ្លួនឯងចំពោះការផ្តល់ការថែទាំដែលមានគុណភាព។ | | |
| **គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់**<br>▪ លើកទឹកចិត្តដល់គិលានុបដ្ឋាក ក្នុងការឆ្លុះបញ្ចាំងពីខ្លួនឯង និង ការពិនិត្យ វាយតម្លៃឡើងវិញដោយសហការី និងការចូលរួមនៅក្នុងការអនុវត្តការងារ ដើម្បីកំណត់និងដោះស្រាយចំណុចខ្វះខាតនិងនិយាមវិជ្ជាជីវៈផ្នែកវិជ្ជាជីវៈដែលជះឥទ្ធិពលទៅលើសម្បទាក្នុងការប្រកបវិជ្ជាជីវៈ។ | | |
| **គិលានុបដ្ឋាកបណ្ឌិត**<br>▪ ចូលរួមនៅកម្រិតថ្នាក់ជាតិនៅក្នុងការអភិវឌ្ឍ ការអនុវត្ត និងពិនិត្យវាយតម្លៃឡើងវិញលើនីតិសម្បទាក្នុងការអនុវត្តគោលនយោបាយសម្រាប់គិលានុបដ្ឋាកនិងយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់ការឆ្លុះបញ្ចាំងពីខ្លួនឯង ការពិនិត្យវាយតម្លៃឡើងវិញរបស់សហការី និងការចូលរួមនៅក្នុងការវាយតម្លៃលើការអនុវត្តការងារ។ | | |

### ២.២.៣ និយាមវិជ្ជាជីវៈនៃការប្រាស្រ័យទាក់ទង ការសហការ និងការតស៊ូមតិ

**និយាមវិជ្ជាជីវៈទី១៧**

គិលានុបដ្ឋាកត្រូវធ្វើការងារក្នុងភាពជាដៃគូជាមួយអតិថិជនដោយទទួលស្គាល់ទំនួលខុសត្រូវបុគ្គលនិងទំនួលខុសត្រូវរួម និងបង្កើតទំនុកចិត្ត និងទំនាក់ទំនងសម្រាប់ការថែទាំតាមបែបវិជ្ជាជីវៈដែលមានការគាំទ្រដោយប្រព្រឹត្តចំពោះអតិថិជន អ្នកមានវិជ្ជាជីវៈសុខាភិបាលដទៃទៀតដោយយកចិត្តទុកដាក់ និងដោយមេត្តាធម៌គ្រប់ពេលវេលា។

*សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ*

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ ធ្វើការងារក្នុងភាពជាដៃគូជាមួយអតិថិជននៅក្នុងការផ្តល់ជូនការថែទាំ ដោយទទួលស្គាល់និងគោរព | ▪ គាំទ្រ និងគ្រប់គ្រងគិលានុបដ្ឋាកបឋមនៅក្នុងការផ្តល់ និងរក្សាបរិយាកាសដែលអនុគ្រោះដល់ | ▪ ត្រួតពិនិត្យ និងវាយតម្លៃដំណើរការប្រាស្រ័យទាក់ទង និងលទ្ធផលនៅក្នុងចំណោមគិលានុបដ្ឋាក |

<table>
<tr>
<td>ចំពោះទំនួលខុសត្រូវបុគ្គល និងទំនួលខុសត្រូវរួម និងប្រព្រឹត្តចំពោះអតិថិជន និងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដទៃទៀតដោយយកចិត្តទុកដាក់និងដោយ មេត្តាធម៌គ្រប់ពេលវេលា។<br>▪ ប្រើប្រាស់ការប្រាស្រ័យទាក់ទងនិងជំនាញទំនាក់ទំនងអន្តរបុគ្គលយ៉ាងមានប្រសិទ្ធភាព ដើម្បីបង្កើតនិងរក្សាភាពជាដៃគូជាមួយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដទៃទៀតដែលមានលក្ខណៈវិជ្ជមានជាមួយអតិថិជននិងគ្រួសារពួកគេក្នុងការផ្តល់ការថែទាំ។</td>
<td>ការថែទាំ ដើម្បីលើកកម្ពស់សុខុមាលភាពរាងកាយ និងផ្លូវចិត្តរបស់អតិថិជន។<br>▪ គាំទ្រ និងគ្រប់គ្រងគិលានុបដ្ឋាកបឋម នៅក្នុងការបង្កើតនិងរក្សាការប្រាស្រ័យទាក់ទងយ៉ាងមានប្រសិទ្ធភាពជាមួយអតិថិជននិងគ្រួសាររបស់ពួកគេ និងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតនៅក្នុងការផ្តល់ការថែទាំ។</td>
<td>អតិថិជននិងគ្រួសារ និងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត និងផ្តល់ការអប់រំនិង គាំទ្រ ឬ អន្តរាគមន៍តាមការចាំបាច់។</td>
</tr>
<tr>
<td colspan="3">គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ ត្រួតពិនិត្យទំនាក់ទំនង និងការប្រាស្រ័យទាក់ទងរវាងគិលានុបដ្ឋាក និងអតិថិជននិងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដទៃទៀត នៅក្នុងផ្នែកឯកទេសនៃការអនុវត្តការថែទាំដែលប្រព្រឹត្តចំពោះអតិថិជនដោយការយកចិត្តទុកដាក់ និងមេត្តាធម៌ ក្នុងក្របខណ្ឌទំនាក់ទំនងគាំទ្រនិងថែទាំតាមបែបវិជ្ជាជីវៈ។</td>
</tr>
<tr>
<td colspan="3">គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ ដើរតួជាគំរូដល់គិលានុបដ្ឋាក ក្នុងការបង្ហាញពីជំនាញទំនាក់ទំនងប្រកបដោយមេត្តា និងមានប្រសិទ្ធភាព និងគាំទ្រគិលានុបដ្ឋាកក្នុងការបង្កើតទំនាក់ទំនងព្យាបាលប្រកបដោយវិជ្ជាជីវៈដែលជឿទុកចិត្ត និងគាំទ្រ។</td>
</tr>
<tr>
<td colspan="3">គិលានុបដ្ឋាកបណ្ឌិត<br>▪ សិក្សាស្រាវជ្រាវនិងបង្ហាញជំនាញក្នុងការប្រាស្រ័យទាក់ទងយ៉ាងមានប្រសិទ្ធភាព នៅក្នុងគ្រប់ទំនាក់ទំនងទាំងអស់ជាមួយគិលានុបដ្ឋាកនិងអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀត ដោយធ្វើការងារក្នុងភាពជាដៃគូជាមួយពួកគេក្នុងករណីអាចធ្វើបាន និងដោយការទទួលស្គាល់និងការគោរពចំពោះទំនួលខុសត្រូវបុគ្គលនិងទំនួលខុសត្រូវរួម។</td>
</tr>
</table>

**និយាមវិជ្ជាជីវៈទី១៨**

គិលានុបដ្ឋាកត្រូវប្រាស្រ័យទាក់ទងយ៉ាងសមស្រប ដោយភាពអោនលំទោន និងយ៉ាងមានប្រសិទ្ធភាព ទាំងពាក្យសម្តី និងកាយវិការ ជាមួយអតិថិជន សហការី អ្នកជំនាញវិជ្ជាជីវៈសុខាភិបាលផ្សេងៗ និងភាគីពាក់ព័ន្ធដទៃទៀត ដោយគោរពចំពោះសេចក្តីថ្លៃថ្នូរ វប្បធម៌ គុណតម្លៃ និងសិទ្ធិរបស់បុគ្គលនីមួយៗ។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

<table>
<tr><th>គិលានុបដ្ឋាកបឋម</th><th>គិលានុបដ្ឋាកបរិញ្ញាបត្ររង</th><th>គិលានុបដ្ឋាកបរិញ្ញាបត្រ</th></tr>
<tr>
<td><ul>
<li>ប្រាស្រ័យទាក់ទងដោយភាពអោនលំទោន និងដោយការគោរពគ្រប់ពេលវេលា ដោយប្រើប្រាស់ជំនាញប្រាស្រ័យទាក់ទងនិងទំនាក់ទំនងអន្តរបុគ្គយ៉ាងមានប្រសិទ្ធភាព ដែលសមស្របតាមវ័យ ភេទ កម្រិតអប់រំ និងវប្បធម៌របស់បុគ្គល និងបង្ហាញឥរិយាបថអាកប្បកិរិយា និងភាសាដែលអាចទទួលយកបាន។</li>
<li>ប្រើប្រាស់អាកប្បកិរិយាប្រាស្រ័យទាក់ទងប្រកបដោយវិជ្ជាជីវៈនិងដោយការគោរព និងអាកប្បកិរិយាទំនាក់ទំនងអន្តរបុគ្គលសមស្របនៅពេលប្រាស្រ័យទាក់ទងជាមួយគិលានុបដ្ឋាកដទៃ និស្សិតគិលា-នុបដ្ឋាក អ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀត។</li>
<li>រក្សាព្រំដែនបុគ្គលផ្ទាល់ខ្លួននិង វិជ្ជាជីវៈឱ្យបានសមស្របជាមួយអតិថិជន និងអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀត នៅពេលផ្តល់ការថែទាំ។</li>
</ul></td>
<td><ul>
<li>គ្រប់គ្រងនិងគាំទ្រដល់គិលានុប-ដ្ឋាកបឋម នៅក្នុងការប្រាស្រ័យទាក់ទងយ៉ាងមានប្រសិទ្ធភាពជាមួយអតិថិជននិងគ្រួសាររបស់ពួកគេ ជាមួយគ្នាទៅវិញទៅមកនិងជាមួយអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀតដែលពាក់ព័ន្ធនឹងការថែទាំអតិថិជន។</li>
<li>ប្រើប្រាស់ជំនាញប្រាស្រ័យទាក់ទងដែលបានអភិវឌ្ឍឡើងដើម្បីប្រាស្រ័យទាក់ទងជាមួយអតិថិជនលំបាកឬកោងកាចនិងសមាជិកគ្រួសាររបស់ពួកគេដើម្បីឆ្លើយតបចំពោះការព្រួយបារម្ភរបស់ពួកគេ និងកាត់បន្ថយភាពកោងកាចឬអារម្មណ៍តានតឹង។</li>
<li>លើកកម្ពស់ការទទួលយកនិងការសម្តែងចេញនូវទស្សនៈផ្សេងៗគ្នា និងគំនិតផ្សេងៗគ្នាដោយលើកទឹកចិត្តឱ្យស្តាប់ គិតពិចារណានូវគំនិតរបស់អ្នកដទៃនិងធ្វើការឆ្លើយតបដែលមិនលម្អៀងប្រកបដោយការគិតពិចារណាគ្រប់ជ្រុងជ្រោយ។</li>
</ul></td>
<td><ul>
<li>ត្រួតពិនិត្យនិងវាយតម្លៃដំណើរការប្រាស្រ័យទាក់ទងនៅកន្លែងការងារ រវាងគិលានុបដ្ឋាកនិងគិលានុបដ្ឋាក និងរវាងគិលានុបដ្ឋាក និងអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀត និងផ្តល់ការអប់រំនិងគាំទ្រ ឬអន្តរាគមន៍ បើចាំបាច់។</li>
</ul></td>
</tr>
<tr><td colspan="3">គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<ul>
<li>ប្រើប្រាស់និងបង្ហាញកម្រិតនៃយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងតាមពាក្យសម្តីនិងកាយវិការ ដែលមានភាពសមស្របនិងមានប្រសិទ្ធភាពសម្រាប់អតិថិជន នៅក្នុងផ្នែកឯកទេសនៃការអនុវត្តការងារថែទាំ និងធ្វើជាអ្នកទំនាក់ទំនងរវាងអតិថិជន គិលានុបដ្ឋាកផ្សេងៗ និងក្រុមការងារពហុវិស័យ។</li>
</ul></td></tr>
</table>

| |
|---|
| គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ បង្កើតបណ្តាញទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពជាមួយរវាងគិលានុបដ្ឋាក និងគិលានុប-ដ្ឋាកនិងក្រុមអ្នកថែទាំសុខភាពដទៃទៀត អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីគាំទ្រដល់ការផ្តល់សេវាថែទាំប្រកបដោយគុណភាព ។ |
| គិលានុបដ្ឋាកបណ្ឌិត<br>▪ ធ្វើជាតំណាងគិលានុបដ្ឋាកនៅក្នុងវេទិកាថ្នាក់ជាតិនិងអន្តរជាតិចម្រុះវិស័យជាន់ខ្ពស់ដែលពាក់ព័ន្ធនឹងការថែទាំ និងសុខាភិបាល ដោយបង្ហាញភាពអោនលំទោន និងការគោរពចំពោះសិទ្ធិ គុណតម្លៃ និងវប្បធម៌របស់អ្នកដទៃនៅក្នុងគ្រប់ទំនាក់ទំនងទាំងអស់។ |

និយាមវិជ្ជាជីវៈទី១៩

គិលានុបដ្ឋាក ត្រូវសហការ និងពិគ្រោះយោបល់ជាមួយគិលានុបដ្ឋាក និងអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀត នៅក្នុងការផ្តល់ការថែទាំដើម្បីលើកកម្ពស់និរន្តរ៍ភាពនៃការថែទាំ។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ ស្វែងរកដំបូន្មាន ឬស្នើសុំជំនួយពីគិលានុបដ្ឋាកផ្សេងទៀត ឬអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀត នៅពេលណាចាំបាច់ក្នុងការផ្តល់ការថែទាំ។<br>▪ រក្សាភាពជាដៃគូសហការជាវិជ្ជមាន និងយ៉ាងមានប្រសិទ្ធភាពនៅក្នុងក្រុមការងារថែទាំ និងជាមួយអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀតដែលពាក់ព័ន្ធនឹងការថែទាំអតិថិជន ដើម្បីលើកកម្ពស់ការថែទាំដែលមានគុណភាព។ | ▪ លើកកម្ពស់នៅកន្លែងការងារដែលលើកទឹកចិត្តឱ្យមានការប្រាស្រ័យទាក់ទងផ្នែកវិជ្ជាជីវៈ កិច្ចសហការ ការពិភាក្សា ការផ្លាស់ប្តូរយោបល់ និងការដោះស្រាយលើវិវាទហើយដែលទទួលស្គាល់ទំនួលខុសត្រូវបុគ្គលនិងទំនួលខុសត្រូវរួមនៅក្នុងក្រុមការងារថែទាំ និងជាមួយអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀត។<br>▪ សម្របសម្រួលផែនការថែទាំដែលបានផ្តល់ជូនដោយការយកចិត្តទុកដាក់ដែលបានផ្តល់ដោយអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀតដើម្បីលើកកម្ពស់និរន្តរ៍ភាពនៃការថែទាំ។ | ▪ ត្រួតពិនិត្យនិងវាយតម្លៃការងារជាក្រុម និងការអនុវត្តបែបសហការ និងឆ្លើយតបយ៉ាងសមស្របដើម្បីដោះស្រាយជម្លោះក្នុងចំណោមគិលានុបដ្ឋាក ឬរវាងគិលានុបដ្ឋាក និងអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀត។ |

| |
|---|
| គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ សហការនិងពិគ្រោះយោបល់ជាមួយគិលានុបដ្ឋាក និងអ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀតនៅក្នុងការផ្តល់ជូនការថែទាំក្នុងនាមជាសមាជិកក្រុមការងារថែទាំសុខភាពយ៉ាងទូលំទូលាយ ដើម្បីលើកកម្ពស់ដល់និរន្តរ៍ភាពនៃការ |

<table>
<tr><td>ថែទាំនៅក្នុងផ្នែកឯកទេសនៃការអនុវត្តការងារថែទាំ។</td></tr>
<tr><td>គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ បង្កើតទំនាក់ទំនងវិជ្ជមានជាមួយគិលានុបដ្ឋាក និងអ្នកជំនាញផ្នែកសុខភាពផ្សេងទៀត ក្នុងការផ្ដល់សេវាថែទាំ ដើម្បីលើកកម្ពស់ការថែទាំបន្ត និងលើកកំពស់លទ្ធផលសុខភាព។</td></tr>
<tr><td>គិលានុបដ្ឋាកបណ្ឌិត<br>▪ ធ្វើជាតំណាងគិលានុបដ្ឋាកនៅក្នុងទំនាក់ទំនងជាមួយស្ថាប័នជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀត ដើម្បីកែលម្អការប្រាស្រ័យទាក់ទង និងកិច្ចសហការនៅថ្នាក់ជាតិក្នុងបណ្ដាជំនាញវិជ្ជាជីវៈនានាដោយធ្វើការងាររួមគ្នាដើម្បីកែលម្អគុណភាពនៃការផ្ដល់ការថែទាំសុខភាព។</td></tr>
</table>

និយាមវិជ្ជាជីវៈទី២០

គិលានុបដ្ឋាកត្រូវតស៊ូមតិទាមទារសិទ្ធិអតិថិជនក្នុងរបៀបមួយដែលគាំទ្រដល់ស្វ័យភាព សេចក្តីថ្លៃថ្នូរ ភាពឯកជន និងសិទ្ធិក្នុងការសម្រេចចិត្តដោយខ្លួនឯង និងការពារសុវត្ថិភាពរបស់ពួកគេ។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ:

<table>
<tr><th>គិលានុបដ្ឋាកបឋម</th><th>គិលានុបដ្ឋាកបរិញ្ញាបត្ររង</th><th>គិលានុបដ្ឋាកបរិញ្ញាបត្រ</th></tr>
<tr><td>▪ តស៊ូមតិដើម្បីការពារសិទ្ធិរបស់អតិថិជននិងគ្រួសាររបស់ពួកគេជាពិសេសការរក្សាបាននូវស្វ័យភាព សេចក្ដីថ្លៃថ្នូរ ភាពឯកជន និងសិទ្ធិធ្វើការសម្រេចចិត្តដោយខ្លួនឯង។</td><td>▪ តស៊ូមតិទាមទារឱ្យមានសេវាថែទាំសម្រាប់ក្រុមជនងាយរងគ្រោះ និងសហគមន៍ដែលពិបាកទាក់ទងជាពិសេសស្ត្រីដែលជួបប្រទះអំពើហិង្សា គ្រប់ទម្រង់ដែលពាក់ព័ន្ធនឹងយេនឌ័រ ឬការមិនយកចិត្តទុកដាក់ឬការប្រព្រឹត្តផ្លូវភេទដែលបង្កគ្រោះថ្នាក់។</td><td>▪ តស៊ូមតិសម្រាប់វិជ្ជាជីវៈគិលានុបដ្ឋាកនៅតាមគ្រឹះស្ថានឬថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីការកែលម្អជាបន្តផ្នែកអប់រំស្តីពី ការថែទាំ ការអនុវត្ត ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ។</td></tr>
<tr><td colspan="3">គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ លើកកម្ពស់ការការពារសិទ្ធិអតិថិជននៅក្នុងផ្នែកឯកទេសនៃការអនុវត្តការងារថែទាំដែលត្រូវប្រព្រឹត្តដោយការគោរពត្រូវផ្តល់ជូននូវភាពឯកជននិងត្រូវគោរពចំពោះស្វ័យភាព និងការសម្រេចចិត្តដោយខ្លួនពួកគេផ្ទាល់ក្នុងរបៀបមួយដែលការពារផងដែរដល់សុវត្ថិភាពរបស់ពួកគេ។</td></tr>
<tr><td colspan="3">គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ លើកកម្ពស់សិទ្ធិរបស់អតិថិជន ព្រមទាំងណែនាំ និងគាំទ្រគិលានុបដ្ឋាកក្នុងការបញ្ចូលការគោរពសិទ្ធិរបស់អតិថិជនទៅក្នុងការផ្ដល់សេវាថែទាំទាំងអស់។</td></tr>
<tr><td colspan="3">គិលានុបដ្ឋាកបណ្ឌិត<br>▪ ធ្វើជាតំណាងឱ្យវិជ្ជាជីវៈគិលានុបដ្ឋាកនៅកម្រិតថ្នាក់ជាតិនៅក្នុងការតស៊ូមតិសម្រាប់សិទ្ធិរបស់អតិថិជនដើម្បីឱ្យមានការឆ្លុះបញ្ចាំងនៅក្នុងគោលនយោបាយ ពិធីសារ និងកម្មវិធីថែទាំសុខភាពថ្នាក់ជាតិទាំងអស់។</td></tr>
</table>

និយាមវិជ្ជាជីវៈទី២១

គិលានុបដ្ឋាកត្រូវតស៊ូមតិ និងរួមចំណែកដល់មជ្ឈដ្ឋានការងារដែលមានសុវត្ថិភាពដែលលើកកម្ពស់ដល់ការថែទាំប្រកប ដោយគុណភាព និងសម្រាប់ការទទួលស្គាល់ការថែទាំនិងសេវាកម្មនានាដែលរក្សាបាននូវសេចក្តីថ្លៃថ្នូរនិងស្វ័យភាពនៃ វិជ្ជាជីវៈគិលានុបដ្ឋាក។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ តស៊ូមតិទាមទារឱ្យមានបរិយាកាសការងារសមស្របសម្រាប់គិលានុបដ្ឋាក ដែលគាំទ្រដល់ការផ្តល់ជូនការថែទាំ និងការអនុវត្តការងារដែលមានសុវត្ថិភាពនិងមានក្រមសីលធម៌។ | ▪ តស៊ូមតិទាមទារឱ្យមានបរិយាកាសការងារសមស្របដែលផ្តល់លក្ខខណ្ឌការងារមានសុវត្ថិភាពសម្រាប់គិលានុបដ្ឋាករួមទាំងវឌ្ឍនភាពនៃអាជីពការងារ ប្រាក់កម្រៃ និងស្ថានភាពសេវាកម្ម។ | ▪ តស៊ូមតិឱ្យមានការបែងចែកគិលានុបដ្ឋាកនិងធនធានសម្ភារៈប្រកបដោយសមធម៌ និងគ្រប់គ្រាន់ដើម្បីផ្តល់ការថែទាំដែលមានសុវត្ថិភាព និងប្រកបដោយគុណភាព។<br>▪ តស៊ូមតិសម្រាប់វិជ្ជាជីវៈគិលានុបដ្ឋាក ដើម្បីការកែលម្អជាបន្តផ្នែកអប់រំស្តីពីការថែទាំការអនុវត្ត ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ។ |
| គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ ស្វែងរកការគាំទ្រឱ្យមានបរិយាកាសការងារសមស្របដែលមានសុវត្ថិភាពសម្រាប់គិលានុបដ្ឋាកដែលកំពុងធ្វើការនៅក្នុងផ្នែកឯកទេសនៃការអនុវត្តការថែទាំ។<br>▪ ស្វែងរកការគាំទ្រកែលម្អជាបន្តនៅក្នុងផ្នែកអប់រំថែទាំ និងវឌ្ឍនភាពអាជីពការងារនៅក្នុងផ្នែកឯកទេសនៃការអនុវត្តការថែទាំ និងការទទួលស្គាល់គិលានុបដ្ឋាកដែលទទួលបានការអប់រំ និងដែលកំពុងធ្វើការងារនៅក្នុងផ្នែកឯកទេស។ | | |
| គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ តស៊ូមតិសម្រាប់វិជ្ជាជីវៈគិលានុបដ្ឋាកនៅ និងការបន្តធ្វើឱ្យប្រសើរឡើងក្នុងការអប់រំ ការអនុវត្ត ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំនៃការថែទាំ ។ | | |
| គិលានុបដ្ឋាកបណ្ឌិត<br>▪ ស្វែងរកការគាំទ្រនិងផ្តល់ការការពារគិលានុបដ្ឋាកនៅកម្រិតថ្នាក់ជាតិសម្រាប់ការទទួលស្គាល់ចំពោះវិជ្ជាជីវៈគិលានុបដ្ឋាក និងសម្រាប់ការកែលម្អនៅក្នុងការអប់រំថែទាំ ស្ថានភាពការងារ ប្រាក់កម្រៃ និងវឌ្ឍនភាពអាជីពការងារ។ | | |

## ២.២.៨ និយាមវិជ្ជាជីវៈនៃការបង្រៀន និងការសិក្សារៀនសូត្រ

និយាមវិជ្ជាជីវៈទី២២

គិលានុបដ្ឋាកត្រូវរួមបញ្ចូលការផ្តល់ព័ត៌មានសុខភាព និងការអប់រំសុខភាពដែលពាក់ព័ន្ធនឹងតម្រូវការអតិថិជន ទៅក្នុងការថែទាំនៅគ្រប់ទីកន្លែងទាំងអស់ដែលពួកគេប្រកបវិជ្ជាជីវៈ។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

| គិលានុបដ្ឋាកបឋម | គិលានុបដ្ឋាកបរិញ្ញាបត្ររង | គិលានុបដ្ឋាកបរិញ្ញាបត្រ |
|---|---|---|
| ▪ រួមបញ្ចូលការផ្តល់ព័ត៌មានសុខភាព ការអប់រំសុខភាព និងសិទ្ធិរបស់អតិថិជនទៅក្នុងការ អនុវត្តការថៃទាំ និងឆ្លើយតបយ៉ាងសមស្រប ទៅនឹងការស្នើសុំព័ត៌មានរបស់អតិថិជន។<br>▪ ចូលរួមក្នុងកម្មវិធីលើកកម្ពស់សុខភាពតាមសហគមន៍ កម្មវិធីអប់រំសុខភាព និងកម្មវិធីបង្ការជំងឺ ដែលមានជាប់ពាក់ព័ន្ធទៅនឹងការផ្តល់ការថៃទាំ។ | ▪ ផ្តល់ព័ត៌មានសមស្របសម្រាប់បុគ្គលនិងគ្រួសារ ការពិគ្រោះយោបល់និងការអប់រំជាពិសេសសម្រាប់សហគមន៍ដែលមានតម្រូវការពិសេស។<br>▪ រួមចំណែកទៅក្នុងការអភិវឌ្ឍនិងការអនុវត្តកម្មវិធីអប់រំសុខភាពតាមសហគមន៍ ដែលលើកកម្ពស់ដល់សុខភាព បង្ការជំងឺ លើកកម្ពស់សមភាព និងដោះស្រាយបញ្ហាអំពើហិង្សាពាក់ព័ន្ធយេនឌ័រ ព្រមទាំងការមិនយកចិត្តទុកដាក់ ឬការអនុវត្តផ្នែកវប្បធម៌ដែលបង្កគ្រោះថ្នាក់ដល់ស្ត្រីនិងក្មេងស្រី។ | ▪ ចុះធ្វើការប៉ាន់ប្រមាណតម្រូវការតាមសហគមន៍ដើម្បីផ្តល់ដំណឹងអំពីការអភិវឌ្ឍនិងការអនុវត្តកម្មវិធីអប់រំសុខភាពសម្រាប់បុគ្គលនិងតាមសហគមន៍។<br>▪ ផ្តល់ព័ត៌មាននិងការអប់រំដល់សហការីគិលានុបដ្ឋាក និងនិស្សិតគិលានុបដ្ឋាកស្តីពីបញ្ហាសុខភាពដែលពាក់ព័ន្ធទៅនឹងការថៃទាំ និងស្តីពីរបកគំហើយថ្មីៗដែលទាក់ទងទៅនិងការអនុវត្តការងារថៃទាំ។<br>▪ ចូលរួមនៅក្នុងការត្រួតពិនិត្យឡើងវិញនិងការបង្រៀននៅក្នុងកម្មវិធីថៃទាំសុខភាពផ្សេងៗ។ |
| គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថៃទាំ<br>▪ រួមបញ្ចូលព័ត៌មាន និងការអប់រំសុខភាពដែលពាក់ព័ន្ធនឹងតម្រូវការអតិថិជន ចូលទៅក្នុងការថៃទាំនៅក្នុងផ្នែកឯកទេសនៃការអនុវត្តការងារថៃទាំ។ | | |
| គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ លើកកម្ពស់វប្បធម៌នៃការសិក្សាជាប្រចាំនិងជាប់រហូតនូវវិជ្ជាជីវៈជាគិលានុបដ្ឋាក និងលើកទឹកចិត្តនិងជម្រុញឱ្យមានការចូលរួមរបស់ពួកគេនៅក្នុងការអភិវឌ្ឍវិជ្ជាជីវៈបន្ត។ | | |
| គិលានុបដ្ឋាកបណ្ឌិត<br>▪ លើកកម្ពស់នៅកម្រិតថ្នាក់ជាតិ និងសម្របសម្រួលដល់ការរួមបញ្ចូលព័ត៌មានសុខភាពនិងការអប់រំសុខភាពសម្រាប់ជាសមាសភាពដ៏សំខាន់មួយនៃការអនុវត្តការថៃទាំនៅគ្រប់ទីកន្លែងទាំងអស់។ | | |

**និយាមវិជ្ជាជីវៈទី២៣**

គិលានុបដ្ឋាកត្រូវកំណត់តម្រូវការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ និងចូលរួមនៅក្នុងការបណ្តុះបណ្តាលជាមួយគិលានុបដ្ឋាកផ្សេងទៀត និស្សិត អ្នកជំនាញវិជ្ជាជីវៈសុខាភិបាលដទៃទៀត និងការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

<table>
<tr><th>គិលានុបដ្ឋាកបឋម</th><th>គិលានុបដ្ឋាកបរិញ្ញាបត្ររង</th><th>គិលានុបដ្ឋាកបរិញ្ញាបត្រ</th></tr>
<tr><td>▪ ធ្វើបច្ចុប្បន្នភាពចំណេះដឹង និងជំនាញផ្នែកថែទាំ តាមរយៈការអភិវឌ្ឍវិជ្ជាជីវៈបន្ត និងការបណ្តុះបណ្តាលជំនាញ "លើការងារជាក់ស្តែង" ដើម្បីរក្សាសមត្ថភាពនៅក្នុងការអនុវត្តការថែទាំ។<br>▪ ធ្វើការឆ្លុះបញ្ចាំងពីខ្លួនឯងការពិនិត្យវាយតម្លៃឡើងវិញដោយសហការី និងការវាយតម្លៃការអនុវត្តការងារ ដើម្បីកែលម្អគុណភាពនៃការថែទាំផ្ទាល់ខ្លួន។</td><td>▪ វាយតម្លៃការអនុវត្តការងារផ្ទាល់ខ្លួនដើម្បីកំណត់តម្រូវការសិក្សារៀនសូត្រ និងធ្វើបច្ចុប្បន្នភាពលើចំណុចខ្វះខាតផ្នែកចំណេះដឹងនិងជំនាញ តាមរយៈការអភិវឌ្ឍវិជ្ជាជីវៈបន្ត។<br>▪ ចូលរួមនៅក្នុងឱកាសអប់រំខាងក្រៅ ដូចជាសន្និសីទ និងដំណើរទស្សនកិច្ចសិក្សាដើម្បីកែលម្អគុណភាពនៃការថែទាំផ្ទាល់ខ្លួន<br>▪ គាំទ្រនិងគ្រប់គ្រងគិលានុបដ្ឋាក។ បឋម និងនិស្សិតគិលានុបដ្ឋាក នៅក្នុងការរក្សាចំណេះដឹងនិងជំនាញរបស់ពួកគេ តាមរយៈការអភិវឌ្ឍវិជ្ជាជីវៈបន្ត។</td><td>▪ លើកកម្ពស់វប្បធម៌ការសិក្សាជាប្រចាំ និងជាប់រហូតនូវវិជ្ជាជីវៈជាគិលានុបដ្ឋាក និងការអភិវឌ្ឍវិជ្ជាជីវៈបន្តនៅក្នុងកន្លែងការងារសម្រាប់គិលានុបដ្ឋាកនិងនិស្សិតគិលានុបដ្ឋាក ដើម្បីកំណត់និងអនុវត្តចំណេះដឹងថ្មីៗនិងឧត្តមភាពនៃការអនុវត្តនៅក្នុងការថែទាំ។</td></tr>
<tr><td colspan="3">គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ ចូលរួមក្នុងការបង្រៀនបែបគ្លីនិក និងទ្រឹស្តីក្នុងកម្មវិធីអប់រំអំពីការថែទាំដែលត្រៀមរៀបចំគិលានុបដ្ឋាកឱ្យបំពេញការងារនៅក្នុងផ្នែកឯកទេសនៃការអនុវត្តការថែទាំ។</td></tr>
<tr><td colspan="3">គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ ផ្តល់ការណែនាំនិងការគាំទ្រដល់គិលានុបដ្ឋាកដែលបញ្ចប់ការសិក្សា និងបម្រើការងារ ព្រមទាំងផ្តល់ការបង្ហាញផ្លូវអំពីការបំពេញការងារនិងការបង្ហាត់បង្រៀននៅកន្លែងបម្រើការងារ។</td></tr>
<tr><td colspan="3">គិលានុបដ្ឋាកបណ្ឌិត<br>▪ ផ្តល់ជំបូន្មានជំនាញនិងធាតុចូលនៅក្នុងការអភិវឌ្ឍ ការពិនិត្យឡើងវិញ និងការវាយតម្លៃលើកម្មវិធីអប់រំថែទាំ និងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈបន្ត។<br>▪ ផ្តល់ការបង្រៀន និងការបង្ហាត់ណែនាំកម្រិតខ្ពស់ដល់អ្នកដឹកនាំគិលានុដ្ឋាកថ្មីៗ។</td></tr>
</table>

### ២.២.៤ និយាមនៃការអនុវត្តផ្អែកលើតស្តុតាង ការសិក្សាស្រាវជ្រាវ និងគុណាភាពនៃការថែទាំ

និយាមវិជ្ជាជីវៈទី២៤

គិលានុបដ្ឋាកត្រូវចូលរួមទៅក្នុងសកម្មភាព នៃការអនុវត្តផ្អែកលើភស្តុតាង សិក្សាស្រាវជ្រាវមានដូចជាការប្រមូលទិន្នន័យអេពីដេមីសាស្ត្រផ្នែកសុខាភិបាល និងសង្គម ការវាយតម្លៃឱ្យបានដិតដល់និងការរួមបញ្ចូលទិន្នន័យនិង លទ្ធផលសិក្សាទៅក្នុងការអនុវត្ត នៅក្នុងនិយាមវិជ្ជាជីវៈនៃការអនុវត្តរបស់ពួកគេ។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

<table>
<tr><th>គិលានុបដ្ឋាកបឋម</th><th>គិលានុបដ្ឋាកបរិញ្ញាបត្ររង</th><th>គិលានុបដ្ឋាកបរិញ្ញាបត្រ</th></tr>
<tr>
<td>▪ ចូលរួមទៅក្នុងការសិក្សាស្រាវជ្រាវ និង ការប្រមូលទិន្នន័យអេពីដេមីសាស្ត្រដែលពាក់ព័ន្ធនឹងការអនុវត្តការថែទាំ។<br>▪ ពិចារណាអំពីផលប៉ះពាល់លើកត្តាសង្គមដែលមានឥទ្ធិពលលើសុខភាព នៅពេលផ្តល់ការថែទាំឱ្យបានគ្រប់ជ្រុងជ្រោយ ។</td>
<td>▪ វាយតម្លៃឱ្យបានដិតដល់ និងរួមបញ្ចូលលទ្ធផលនៃការសិក្សាស្រាវ ជ្រាវទៅក្នុងការអនុវត្តការថែទាំ និងរួមចំណែកនៅក្នុងគំនិតផ្តួចផ្តើមសិក្សាស្រាវជ្រាវ ដើម្បីកែលម្អការថែទាំផ្អែកលើភស្តុតាងជាក់ស្តែង។<br>▪ រួមបញ្ចូលកត្តាសង្គមដែលមានឥទ្ធិពលលើសុខភាពនៅក្នុងការប៉ាន់ប្រមាណនិងការធ្វើផែនការថែទាំ និងរួមចំណែកទៅក្នុងការប្រមូលទិន្នន័យអេពីដេមីសាស្ត្រ ការបកស្រាយនិងការវិភាគលទ្ធផលដើម្បីកែលម្អគុណភាពនៃការថែទាំ។<br>▪ រក្សាចំណេះដឹងផ្ទាល់ខ្លួនអំពីជំងឺថ្មីៗនាពេលបច្ចុប្បន្ន បច្ចេកវិទ្យាថ្មីៗ កម្មវិធីថ្មីៗ និងបែបបទនៃការថែទាំថ្មីៗដែលពាក់ព័ន្ធទៅនឹងការថែទាំវិជ្ជាជីវៈគិលានុបដ្ឋាក។</td>
<td>▪ ផ្តួចផ្តើម និងធ្វើការសិក្សាស្រាវជ្រាវ ដើម្បីរួមចំណែកនៅក្នុងការបង្កើនចំណេះដឹងស្តីពីការថែទាំ និងធ្វើការចងក្រង និងផ្សព្វផ្សាយលទ្ធផលសិក្សាស្រាវជ្រាវ ដើម្បីលើកកម្ពស់ការអនុវត្តផ្អែកតាមភស្តុតាងជាក់ស្តែង។<br>▪ ផ្តួចផ្តើមបង្កើតការប្រមូលផ្តុំការវិភាគ និងបកស្រាយទិន្នន័យ អេពីដេមីសាស្ត្រតាមសហគមន៍និងសង្គមដើម្បីកំណត់អំពីភាពខ្វះចន្លោះ និងធ្វើការណែនាំបញ្ចូលសម្រាប់ការកែលម្អគុណភាពនៃការថែទាំ។<br>▪ ត្រួតពិនិត្យនិងវាយតម្លៃទិន្នន័យតាមដានជំងឺ ដែលមានឥទ្ធិពលទៅលើការថែទាំ និងសហការជាមួយភាគីពាក់ព័ន្ធខាងក្នុងនិងខាងក្រៅនៅក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រដើម្បីបង្ការនិងគ្រប់គ្រងជំងឺថ្មីៗនាពេលបច្ចុប្បន្ន។</td>
</tr>
<tr><td colspan="3">គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ កំណត់ឱកាសក្នុងការសិក្សាស្រាវជ្រាវ និងចូលរួមក្នុងការសិក្សាស្រាវជ្រាវ នៅផ្នែកឯកទេសនៃការអនុវត្តការថែទាំ។</td></tr>
<tr><td colspan="3">គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ ចូលរួមក្នុងគំនិតផ្តួចផ្តើមស្រាវជ្រាវជាតិ និងអន្តរជាតិ និងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវតាមរយៈសិក្ខាសាលា ឬបទបង្ហាញសន្និសីទ និងការបោះពុម្ពផ្សាយក្នុងទិនានុប្បវត្តិវិជ្ជាជីវៈពាក់ព័ន្ធ។</td></tr>
<tr><td colspan="3">គិលានុបដ្ឋាកបណ្ឌិត<br>▪ សរសេរគំរោងសំណើសិក្សាស្រាវជ្រាវ និងដាក់ប្រគល់សំណើដើម្បីស្នើសុំមូលនិធិឧបត្ថម្ភសម្រាប់ការសិក្សាស្រាវជ្រាវ។<br>▪ រចនានិងចុះធ្វើការសិក្សាស្រាវជ្រាវដោយផ្អែកលើគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ និងប្រែក្លាយលទ្ធផលសិក្សាស្រាវជ្រាវឱ្យទៅជាការកែលម្អគុណភាពនៃការថែទាំ។</td></tr>
</table>

| |
|---|
| ▪ ផ្សព្វផ្សាយការសិក្សាស្រាវជ្រាវដោយបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីស្រាវជ្រាវ ឬសៀវភៅ ឬធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលានិងសន្និសីទ។ |

និយាមវិជ្ជាជីវៈទី២៥

គិលានុបដ្ឋាក ត្រូវរួមចំណែកនិងចូលរួមទៅក្នុងការអភិវឌ្ឍ ការអនុវត្ត និងការវាយតម្លៃលើគំនិតផ្តួចផ្តើមនិងកម្មវិធី កែលម្អគុណភាពដើម្បីកែលម្អក្នុងផ្នែកវិទ្យាសាស្ត្រថែទាំ ។

សូចនាករអនុវត្តនិយាមវិជ្ជាជីវៈ

<table>
<tr><th>គិលានុបដ្ឋាកបឋម</th><th>គិលានុបដ្ឋាកបរិញ្ញាបត្ររង</th><th>គិលានុបដ្ឋាកបរិញ្ញាបត្រ</th></tr>
<tr><td>▪ ចូលរួមទៅក្នុងការធ្វើសវនកម្មអំពីការកើតជំងឺ និងមរណៈ និងសវនកម្មជំងឺដែលជិតនឹងមានគ្រោះថ្នាក់ និងការអភិវឌ្ឍនិងការអនុវត្តគំនិតផ្តួចផ្តើមកែលម្អគុណភាពដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រថែទាំ។</td><td>▪ ប្រើប្រាស់ក្របខណ្ឌកែលម្អគុណភាពដែលមានផ្តល់ជូន ដើម្បីកែលម្អផ្នែកវិទ្យាសាស្ត្រថែទាំនៅកន្លែងបម្រើការងារ។<br>▪ លើកកម្ពស់គោលការណ៍កែលម្អគុណភាព និងផ្តល់ព័ត៌មាន និងការអប់រំនៅក្នុងកន្លែងបម្រើការងារស្តីពីឧបករណ៍កែលម្អគុណភាព។</td><td>▪ ផ្តួចផ្តើមបង្កើតនិងដឹកនាំការអនុវត្តសកម្មភាពកែលម្អគុណ-ភាព នៅកន្លែងបម្រើការងាររួមទាំងការស្ទង់មតិលើការពេញចិត្តរបស់អតិថិជន។</td></tr>
<tr><td colspan="3">គិលានុបដ្ឋាកដែលបម្រើការក្នុងផ្នែកឯកទេសនៃការថែទាំ<br>▪ ផ្តួចផ្តើមនិងដឹកនាំការអភិវឌ្ឍនិងការអនុវត្តសកម្មភាពកែលម្អគុណភាពនៅក្នុងវិស័យជំនាញឯកទេសនៃវិទ្យាសាស្ត្រថែទាំ។</td></tr>
<tr><td colspan="3">គិលានុបដ្ឋាកបរិញ្ញាបត្រជាន់ខ្ពស់<br>▪ ផ្តួចផ្តើម និងដឹកនាំការអភិវឌ្ឍ និងការអនុវត្តសកម្មភាពលើកកម្ពស់គុណភាព រួមទាំងការស្ទង់មតិការពេញចិត្តរបស់អតិថិជន និងអនុវត្តយុទ្ធសាស្ត្រកែលម្អគុណភាព ដើម្បីកាត់បន្ថយអត្រាឈឺ និងអត្រាមរណភាពរបស់អតិថិជន។</td></tr>
<tr><td colspan="3">គិលានុបដ្ឋាកបណ្ឌិត<br>▪ ផ្តល់ជំបូន្មានជំនាញនិងជាតុចូលទៅក្នុងការរចនាបង្កើតនិងការអនុវត្តគំនិតផ្តួចផ្តើមកែលម្អគុណភាពកម្រិតថ្នាក់ជាតិដើម្បីកែលម្អការថែទាំអតិថិជន។</td></tr>
</table>

## ឧបសម្ព័ន្ធ

## សេចក្តីសម្រេចលេខ......០១...៤សគគ ចុះថ្ងៃទី២៨..ខែមេសា ឆ្នាំ២០២២

## ស្តីពី

## ការដាក់ឱ្យអនុវត្តនូវចរិយាបថវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាក នៅក្នុងព្រះរាជាណាចក្រកម្ពុជា

## ឧបសម្ព័ន្ធ ១៖ តារាងសមាជិកក្រុមការងារបច្ចេកទេស

**តំណាងមកពីគណៈគិលានុបដ្ឋាកកម្ពុជា**

| | |
|---|---|
| ១.លោកអនុបណ្ឌិត អ៊ុន សាន | ប្រធានគណៈគិលានុបដ្ឋាកកម្ពុជា |
| ២.លោក មាស សារិទ្ធ | អនុប្រធានគណៈគិលានុបដ្ឋាកកម្ពុជា |
| ៣.លោក ថៃ សុវណ្ណារ៉ា | អនុប្រធានគណៈគិលានុបដ្ឋាកកម្ពុជា |
| ៤. លោក ប្រុញ សុមិត្ត | អគ្គលេខាធិការគណៈគិលានុបដ្ឋាកកម្ពុជា |
| ៥. លោកស្រី ម៉ៅ តាន់ណារី | អគ្គហិរញ្ញិកគណៈគិលានុបដ្ឋាកកម្ពុជា |
| ៦. លោក ហ៊ុន សេរីវឌ្ឍនា | អគ្គហិរញ្ញិករងគណៈគិលានុបដ្ឋាកកម្ពុជា |
| ៧. លោកស្រី ប៉ែន មុំ | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |

**តំណាងមកពីមន្ទីរពេទ្យថ្នាក់ជាតិ**

| | |
|---|---|
| ១.លោក គឹម ចន្ថា | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិមន្ទីរពេទ្យកុមារជាតិ |
| ២.លោក ឌុច សុខា | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិមន្ទីរពេទ្យមិត្តភាពខ្មែរសៀត |
| ៣.លោក ជី សម្បត្តិ | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិមន្ទីរពេទ្យកាល់ម៉ែត |
| ៤.លោក ជា សុភក្តិមុនីរ័ត្ន | អនុប្រធានក្រុមប្រឹក្សា គណៈគិលានុបដ្ឋាកជាតិមន្ទីរពេទ្យកាល់ម៉ែត |
| ៥.លោកស្រី កង ឡុងឆវីណ្ណ | អនុប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិមន្ទីរពេទ្យខ្មែរចិន |

**តំណាងមកពីភូមិភាគ**

| | |
|---|---|
| ១.លោកស្រី អ៊ឹម វណ្ណារី | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិរាជធានីភ្នំពេញ |
| ២.លោក វង់ វិចិត្ត | តំណាងផ្នែកហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ ភូមិភាគកំពង់ឆ្នាំង |
| ៣.លោក យិន ហួង | តំណាងផ្នែកហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ ភូមិភាគបាត់ដំបង |
| ៤.លោក អ៊ឹម សំបូ | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ ភូមិភាគប៉ៃលិន |
| ៥.លោក យិន វិបុល | ប្រធានក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ ភូមិភាគកំពង់ចាម |
| ៦.លោក លឹម សុភក្តិ | អនុប្រធានក្រុមប្រឹក្សា គណៈគិលានុបដ្ឋាកកម្ពុជា ភូមិភាគត្បូងឃ្មុំ |
| ៧.លោក យក់ សុថា | តំណាងក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ ភូមិភាគបាត់ដំបង |
| ៨.លោក គង់ សុវណ្ណ | តំណាងក្រុមប្រឹក្សា គណៈគិលានុបដ្ឋាកកម្ពុជា ភូមិភាគបាត់ដំបង |
| ៩.លោក ជា ប៉ុម្ប៊ | តំណាងក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិ ភូមិភាគបាត់ដំបង |



San

## តំណាងមកពីមន្ទីរពេទ្យរបស់អង្គការក្រៅរដ្ឋាភិបាល

| | |
|---|---|
| លោក អឿន ចន្ទី | តំណាងក្រុមប្រឹក្សាគណៈគិលានុបដ្ឋាកជាតិមន្ទីរពេទ្យអង្គការក្រៅរដ្ឋាភិបាលមជ្ឈមណ្ឌលនៃក្តីសង្ឃឹមព្រះសីហនុ |
| លោក ដួង វិបុល | នាយកផ្នែកបណ្តុះបណ្តាលនៃមន្ទីរពេទ្យកុមារអង្គរ |

## តំណាងមកពីដៃគូអភិវឌ្ឍ

| | |
|---|---|
| ១.លោក លី ច័ន្ទវឌ្ឍនៈ | ទីប្រឹក្សាបច្ចេកទេសនីយ័តកម្ម និងគាំទ្រការអភិវឌ្ឍគណៈវិជ្ជាជីវៈសុខាភិបាល នៃគម្រោងលើកកម្ពស់សេវាថែទាំសុខភាពរបស់ទីភ្នាក់ងារជំនួយសហរដ្ឋអាមេរិក (USAID-EQHA) |
| ២.លោក ឡេង វឌ្ឍនៈ | មន្ត្រីគម្រោង USAID-EQHA |
| ៣.លោកស្រី Jill Illiffe | អ្នកផ្តល់ប្រឹក្សាយោបល់របស់សហព័ន្ធឆ្មប និងគិលានុបដ្ឋាកខំមិនវែលស៍ |

## ឧបសម្ព័ន្ធ ២៖ បញ្ជីឯកសារដែលត្រូវបានសិក្សាពិនិត្យ

1. ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈគិលានុបដ្ឋាកកម្ពុជា ឆ្នាំ២០០៧
2. ច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ឆ្នាំ២០១៦
3. អនុក្រឹត្យស្តីពីក្រមសីលធម៌គិលានុបដ្ឋាក ឆ្នាំ២០១៤
4. ក្របខណ្ឌសមត្ថភាពស្នូលសម្រាប់បរិញ្ញាបត្រគិលានុបដ្ឋាក ឆ្នាំ២០១២
5. គោលការណ៍ណែនាំសម្រាប់និយាមវិជ្ជាជីវៈនៃការថែទាំអ្នកជំងឺនៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៥
6. គោលនយោបាយជាតិនៃការថែទាំជំងឺ ឆ្នាំ២០០៥
7. ប្រកាសស្តីពីការកំណត់តួនាទីនិងភារកិច្ចរបស់គិលានុបដ្ឋាក-យិកា ឆ្នាំ២០០៣
8. គោលការណ៍ណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់គិលានុបដ្ឋាក ឆ្នាំ២០១៧
9. តួនាទី និងភារកិច្ចរបស់អ្នកគ្រប់គ្រងការថែទាំនៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០០២
10. អាជ្ញាធរគ្រប់គ្រងការថែទាំសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៦ (ក្រសួងសុខាភិបាល)
11. ការរៀបចំការទទួលស្គាល់ទៅវិញទៅមករបស់អាស៊ានលើសេវាថែទាំ ឆ្នាំ២០០៦
12. ព្រឹត្តិបត្រព័ត៌មានស្តីពីការអនុវត្តការរៀបចំការទទួលស្គាល់ទៅវិញទៅមករបស់អាស៊ានលើសេវាថែទាំនៅក្នុងប្រទេសកម្ពុជា
13. ផែនការអភិវឌ្ឍកម្លាំងពលកម្មក្នុងវិស័យសុខាភិបាលកម្ពុជា ឆ្នាំ២០១៦-២០២០
14. គោលការណែនាំប្រតិបត្តិស្តីពីសំណុំសកម្មភាពអប្បបរមា ឆ្នាំ២០១៨
15. គោលការណ៍ណែនាំប្រតិបត្តិការស្តីពីសំណុំសកម្មភាពបង្គ្រប់សម្រាប់មន្ទីរពេទ្យបង្អែក ឆ្នាំ២០១៤
16. ផែនការយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាលកម្ពុជា ឆ្នាំ២០១៥-២០១៩
17. ក្រុមប្រឹក្សាអន្តរជាតិនៃនិយាមវិជ្ជាជីវៈអនុវត្តរបស់គិលានុបដ្ឋាក និងក្របខណ្ឌនៃការសម្រេចចិត្ត ឆ្នាំ២០១០
18. និយាមវិជ្ជាជីវៈអនុវត្តនិងនិយាមវិជ្ជាជីវៈរបស់សមាគមគិលានុបដ្ឋាកអាមេរិក ឆ្នាំ២០១០ និង២០១៥
19. និយាមវិជ្ជាជីវៈនៃការថែទាំនៅប្រទេស អូស្ត្រាលី (វិចតូរីយ៉ា) ឆ្នាំ២០០៦
20. ការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈរបស់ក្រុមប្រឹក្សាភិបាលឆ្មប និងការថែទាំរបស់ប្រទេសអូស្ត្រាលី ឆ្នាំ២០១៣
21. ក្របខណ្ឌសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលឆ្មប និងការថែទាំនៃប្រទេសអូស្ត្រាលី ឆ្នាំ២០០៦
22. ការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈរបស់គិលានបដ្ឋាកប្រទេសប៊ុតស្វាណា ឆ្នាំ២០១៨
23. ក្រមប្រតិបត្តិវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាក និងឆ្មបរបស់ប្រទេសប្រ៊ុយណេ
24. ក្របខណ្ឌសម្រាប់ការអនុវត្តរបស់គិលានុបដ្ឋាកដែលបានចុះបញ្ជិកានៃសមាគមគិលានុបដ្ឋាកកាណាដា ឆ្នាំ២០១៥



Sm

25. ក្របខណ្ឌគ្រប់គ្រងកិច្ចការឆ្មប និងការថែទាំរបស់សាកលវិទ្យាល័យឯកទេសគិលានុបដ្ឋាក ភាគខាងកើត កណ្តាល និងខាងត្បូង ឆ្នាំ២០០១

26. ក្របខណ្ឌការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈវិជ្ជាជីវៈឆ្មប និងការថែទាំរបស់ប្រទេសអៀរឡង់ ឆ្នាំ២០១៥

27. ការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈរបស់គិលានុបដ្ឋាក របស់ប្រទេសកេនយ៉ា ឆ្នាំ២០១២

28. គោលការណ៍ណែនាំស្តីពីការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈការថែទាំរបស់ប្រទេសឡាវ ឆ្នាំ២០០៧

29. ក្រមប្រតិបត្តិវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាក របស់ប្រទេសម៉ាឡេស៊ី

30. និយាមវិជ្ជាជីវៈនៃការប្រតិបត្តិការថែទាំវិជ្ជាជីវៈរបស់ប្រទេសនូវេលហ្សេឡង់ ឆ្នាំ២០១០

31. ការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈរបស់គិលានុបដ្ឋាកដែលបានចុះបញ្ជិកា ឆ្នាំ២០១៦ របស់ប្រទេសនូវេលហ្សេឡង់ ដែលបានមក ពីhttps://www.nursingcouncil.org.nz/Public/Nursing/Scopes_of_practice/Registered_Nurse/NCNZ/nursing-section/Registered_nurse.aspx

32. និយាមវិជ្ជាជីវៈវិជ្ជាជីវៈនៃការអនុវត្តការងារឆ្មប និងការថែទាំ ឆ្នាំ២០១៩ របស់ប្រទេសសិង្ហបុរី

33. ការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈសម្រាប់គិលានុបដ្ឋាកនិងឆ្មប ឆ្នាំ២០១១ របស់ប្រទេសសិង្ហបុរី

34. ទំនាក់ទំនងរវាងការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈ ការដាក់ឱ្យអនុវត្តនូវនិយាមវិជ្ជាជីវៈ និងសមត្ថភាព ឆ្នាំ២០០៥ របស់ក្រុមប្រឹក្សាគិលានុបដ្ឋាកប្រទេសអាហ្វ្រិកខាងត្បូង

35. សៀវភៅមគ្គុទេសក៍ការកែលម្អគុណភាព FHI360 ឆ្នាំ២០១៧

36. Sakurai-Doi, Y. et al អ្នកផ្តល់សេវាថែទាំនៅក្នុងមន្ទីរពេទ្យកម្ពុជា ទស្សនាវដ្តីស្រាវជ្រាវ International Journal of Nursing Practice ឆ្នាំ២០១៤; ឆ្នាំទី២០ (លេខបន្ថែមទី១) ទំព័រ ៣៩-៤៦

37. Tamura, T. et al ស្ថានភាពបច្ចុប្បន្ននៃក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងការថែទាំនៅក្នុងប្រទេសឡាវ កម្ពុជា វៀតណាម និងមីយ៉ាន់ម៉ា ទស្សនាវដ្តីស្រាវជ្រាវ Journal of International Health ឆ្នាំ២០១៥ ឆ្នាំទី៣០ លេខទី២

38. Peng, H., Phallack, K. and Menzel, J. (eds) សញ្ញាណនៃច្បាប់កម្ពុជា ឆ្នាំ២០១២

39. ឯកសារបណ្តុះបណ្តាលស្តីពីដំណើរការថែទាំ ក្រសួងសុខាភិបាល-នាយកដ្ឋានមន្ទីរពេទ្យ ឆ្នាំ២០១២

40. Orlando, I.J. 1972, គោលការណ៍ណែនាំ និង ការបង្រៀនអំពីដំណើរការថែទាំ G.P. Putnam's Sons

41. American Nurses Association. The Nursing Process. Available from: http://www.nursingworld.org/EspeciallyForYou/Whatis Nursing/ToolsYouNeed/Thenursingprocess.html



Sm

រៀបចំ និងបោះពុម្ពដោយ

គណៈកិលានុបដ្ឋាកកម្ពុជា

CAMBODIAN COUNCIL OF NURSES

សហការរៀបចំ និងឧបត្ថម្ភដោយ

USAID FROM THE AMERICAN PEOPLE

fhi360 THE SCIENCE OF IMPROVING LIVES